**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

| | |
|---|---|
| សំណុំរឿងលេខ៖ | ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៦០) |
| ភាគីដាក់ឯកសារ៖ | អោ អាន |
| ដាក់ជូន៖ | អង្គបុរេជំនុំជម្រះ |
| ភាសាដើម៖ | អង់គ្លេស |
| កាលបរិច្ឆេទឯកសារ៖ | ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៩ |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 22-Apr-2019, 14:31
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សម្ងាត់

ចំណាត់ថ្នាក់ឯកសារដោយអង្គបុរេជំនុំជម្រះ៖ **សម្ងាត់/Confidential**

ចំណាត់ថ្នាក់ប្រភេទឯកសារ៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីកត់ត្រា៖

ហត្ថលេខា៖

---

**ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២**

---

| **ដាក់ដោយ៖** | **ផ្ញើជូន៖** | |
|---|---|---|
| **សហមេធាវីការពារក្ដី អោ អាន** | **ចៅក្រមអង្គបុរេជំនុំជម្រះ** | **សហព្រះរាជអាជ្ញា** |
| មុំ លុជ្ស | ចៅក្រម ប្រាក់ គឹមសាន | ជា លាង |
| Richard ROGERS<br>Göran SLUITER | ចៅក្រម Olivier BEAUVALLET | Nicholas KOUMJIAN |
| | ចៅក្រម ន័យ ថុល | |
| | ចៅក្រម BAIK Kang Jin | |
| | ចៅក្រម ហួត វុទ្ធី | |
| | **អ្នកដាក់ពាក្យសុំតាំងខ្លួនធ្វើជាដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់ក្នុងសំណុំរឿង ០០៤/២** | |

# មាតិកា

**សេចក្ដីផ្ដើម**........................................................................................................................ 5

**ទឡ្ហីករណ៍នៅក្នុងការឆ្លើយតប**........................................................................................ 7

I. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះមូលដ្ឋានទី១ នៃបណ្ដឹងឧទ្ធរណ៍ ៖ ច្បាប់ពាក់ព័ន្ធពុំអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដោយឡែកពីគ្នា និងកំណត់ថា ដីកាលើកលែងការចោទប្រកាន់ ត្រូវអនុវត្ត។ .................................................................................................. 7

ក. ទឡ្ហីករណ៍លើខ្លឹមសារអត្ថបទ.................................................................................... 8

ខ. ទឡ្ហីករណ៍ស្ដីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ .........................................10

គ. ដំណោះស្រាយ ............................................................................................................13

II. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះមូលដ្ឋានទី៣ នៃបណ្ដឹងឧទ្ធរណ៍ ៖ សហព្រះរាជអាជ្ញាអន្តរជាតិ ជ្រើសរើសតាមអំពើចិត្តចំពោះផ្នែកនៃប្រវត្តិចរចា ដើម្បីព្យាយាមពង្រីកយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក..........................................................................................................14

III. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៥ នៃបណ្ដឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ មិនចាប់អារម្មណ៍ និងយល់ច្រឡំចំពោះយុត្តិសាស្ត្ររបស់ អង្គបុរេជំនុំជម្រះ និង មិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិតជាបានវាយតម្លៃពីភាពជឿជាក់បានយ៉ាងពេញលេញ និង ត្រឹមត្រូវ ..............................17

ក. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានច្រាល និង បដិសេធដោយផ្ទាល់ មិនអនុវត្តតាមសេចក្ដីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងការវាយតម្លៃភ័ស្តុតាង..................................................18

ខ. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានវាយតម្លៃឱ្យបានត្រឹមត្រូវលើភាពជឿជាក់បានរបស់សាក្សីគន្លឹះ និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីទេ ហើយទោះបីមានអសង្គតិភាពសំខាន់ៗ និងមានការព្រួយបារម្ភលើបញ្ហានៃភាពជឿជាក់ផ្សេងៗទៀតក៏ដោយ ក៏គាត់នៅតែពឹងផ្អែកជាចម្បងទៅលើសក្ខីកម្មរបស់បុគ្គលទាំងនោះដែរ ដោយគ្មានការពន្យល់អ្វីទាំងអស់.......................................................21

គ. មេធាវីការពារក្ដីមិនលើកយកបញ្ហាទាំងនេះមកធ្វើជាចំណុចវិវាទសាជាថ្មីទេ តែផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ យល់ច្រឡំចំពោះសាលដីកាស្ដីពីភាពលម្អៀងរបស់ អង្គបុរេជំនុំជម្រះ .....................24

IV. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៦ នៃបណ្ដឹងឧទ្ធរណ៍៖ ផ្ទុយពីការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ការធ្វើសេចក្ដីសន្និដ្ឋានលើអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងយុត្តាធិការបុគ្គល ជារឿងមិនត្រឹមត្រូវ និងគ្មានភ័ស្តុតាងគាំទ្រ

.................................................................................................................... 26

ក. សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសចំពោះទឡ្ហីករណ៍របស់ អោ អាន ទាក់ទិននឹងភ័ស្តុតាង

ចចាមអារ៉ាម ....................................................................................................27

ខ. សហព្រះរាជអាជ្ញាអន្តរជាតិ យល់ខុសចំពោះទស្សនៈនៃភស្តុតាងបញ្ជាក់បន្ថែម...........................28

គ. សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញភ័ស្តុតាងខុសក្នុងការព្យាយាមធ្វើយុត្តិកម្មចំពោះកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ.............................................................................31

V. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៧ នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ បង្វែរ និង រើសយកតាមការចង់បានរបស់ខ្លួន នូវទឡ្ហីករណ៍របស់ អោ អាន អំពីកំហុសអង្គហេតុ និង អង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់ ........................32

VI. ការឆ្លើយតបចំពោះចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅលើមូលដ្ឋានបណ្តឹងឧទ្ធរណ៍ ៨, ៩, ១១, ១២, ១៤, ១៥ និង ១៦(១)៖ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបដិសេធទៅលើកំហុសឆ្គងអង្គច្បាប់ដែលមេធាវីការពារក្តីបានកំណត់ ទាក់ទងវិធីសាស្ត្ររបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេច និងការអនុវត្ត ច្បាប់ទំនៀមទម្លាប់អន្តរជាតិ...................................................................................33

ក. សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានគិតអំពីភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបង្ហាញឲ្យបានគ្រប់គ្រាន់ ពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ...........................................34

ខ. សហព្រះរាជអាជ្ញាអន្តរជាតិ មិនពិចារណាអំពីសារសំខាន់នៃការត្រួតពិនិត្យទៅលើប្រភពផ្សេងទៀតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្រៅពីយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច ......................................37

VI. ការឆ្លើយតបចំពោះចម្លើយ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅលើមូលដ្ឋានទី១០នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញថា កម្រិតនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានកំណត់ និងអនុវត្តដោយត្រឹមត្រូវនោះទេ ..........................................................................................................39

VIII. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី១៤(I)៖ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងដោយមានកំហុសថា អំពើដោយឡែកៗពីគ្នាជាច្រើន អាចត្រូវបានសំអាងដើម្បីបំពេញលក្ខខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត ..........................................................................

..............................................................................................................42

IX. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី១៦(III) នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងមិនត្រឹមត្រូវពីទឡ្ហីករណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងចេតនាជាក់លាក់នៃបទប្រល័យពូជសាសន៍.........................................................................................43

X. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី១៧ នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបង្ហាញថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍.................................................................................................................44

XI. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី ១៤(II) ១៦(II)

១៦(III) និង ១៧ នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានពុំបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញយ៉ាងសមហេតុផលថា ធាតុផ្សំផ្លូវច្បាប់នៃបទឧក្រិដ្ឋ ត្រូវបានបង្ហាញគ្រប់គ្រាន់..........45

XII. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី១៨ នៃបណ្តឹងឧទ្ធរណ៍៖ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន ត្រូវបានរំលោភនៅគ្រប់កិច្ចដំណើរការនីតិវិធី 45

**សេចក្តីសន្និដ្ឋាន និងសំណើសុំ**.......................................................................................50

# សេចក្តីផ្តើម

1. អោ អាន តាមរយៈសហមេធាវី (បន្ទាប់ពីនេះហៅកាត់ថា "មេធាវីការពារក្តី") សូមគោរពដាក់ការឆ្លើយតបទៅនឹង *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២* (បន្ទាប់ពីនេះហៅកាត់ថា "*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ*)[1] អនុលោមតាមវិធាន ៧៤ នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("*អ.វ.ត.ក*")[2] មាត្រា ៨.៤ នៃសេចក្តីណែនាំអនុវត្តរបស់ អ.វ.ត.ក[3] និង *សាលដីកាលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់សម្រាប់ចម្លើយតប និងការឆ្លើយតប ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង ០០៤/២*[4]។

2. *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* ខកខានមិនបានជំទាស់តវ៉ាទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* (បន្ទាប់ពីនេះហៅកាត់ថា "*បណ្តឹងឧទ្ធរណ៍របស់ អោ អាន*")[5] ពាក់ព័ន្ធនឹងកំហុសអង្គហេតុ និងអង្គច្បាប់ជាច្រើនរបស់សហចៅក្រមស៊ើប

---

[1] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស/អ.ប.ជ ៦០ *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អោ អាន ប្រឆាំងនឹងដីកាសម្រេចបញ្ជូនរឿងទៅជំនុំជម្រះក្នុងសំណុំរឿង ០០៤/២* ឯកសារ D360/9 ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៩។

[2] *វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង")* វិសោធនកម្មលើកទី៩ ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ វិធាន ៧៤។

[3] *សេចក្តីណែនាំអនុវត្តអំពីការដាក់ឯកសារនៅ អ.វ.ត.ក* វិសោធនកម្មលើកទី៨ អ.វ.ត.ក/០១/២០០៧/វិ.លើកទី៨ ដែលបានកែប្រែនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១៤ សេចក្តីណែនាំអនុវត្ត មាត្រា ៨.៤។

[4] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស (អ.ប.ជ ៦០) *សាលដីកាលើសំណើសុំបន្ថែមពេលវេលា និងបង្កើនចំនួនទំព័រកំណត់ សម្រាប់ចម្លើយតប និងការឆ្លើយតប ទាក់ទងនឹងបណ្តឹងឧទ្ធរណ៍នានាប្រឆាំងដីកាដំណោះស្រាយទាំងពីរក្នុងសំណុំរឿង ០០៤/២* ឯកសារ D360/5/3 ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ ទំព័រ ៣-៤។

[5] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ៥៦) *បណ្តឹងឧទ្ធរណ៍របស់ អោ អាន លើដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ* ("*បណ្តឹងឧទ្ធរណ៍របស់ អោ អាន*") ឯកសារ D360/5/1 ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៨។

អង្កេតអន្តរជាតិ ("ស.ច.ស.អ") នៅក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*[6]។ ផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ ("*ស.ព.អ*") យល់ខុស ឬលើកឡើងខុសអំពីទឡ្ហីករណ៍របស់មេធាវីការពារក្តី និងពង្រីកច្បាប់ជាធរមាន និងអង្គហេតុ ដើម្បីប៉ុនប៉ងផ្តល់យុត្តិកម្ម ឬគេចពីកំហុសអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

3. ជាពិសេសជាងនេះ នៅពេលឆ្លើយតបទៅនឹងមូលដ្ឋានទី១ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានតវ៉ាលើទឡ្ហីករណ៍ថា ការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នានៅក្នុងរឿងក្តីតែមួយ គឺជាកំហុសអង្គច្បាប់ ហើយមានភាពអយុត្តិធម៌ចំពោះ អោ អាន។ ឆ្លើយតបទៅនឹងមូលដ្ឋានទី៣នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើការវិភាគដោយមានកំហុសលើប្រវត្តិនៃការចរចាបស់ អ.វ.ត.ក ជ្រើសរើសទៅតាមអំពើចិត្តចំពោះផ្នែកនៃប្រវត្តិចរចា និងខកខានមិនបានពិចារណាលើទឡ្ហីករណ៍ក្នុងវិធីមួយប្រកបដោយអត្ថន័យ។ នៅពេលឆ្លើយតបទៅនឹងមូលដ្ឋានទី៥ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ មិនអើពើទៅនឹងយុត្តិសាស្ត្ររបស់ អង្គបុរេជំនុំជម្រះ និងខកខានមិនបានបង្ហាញថាសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃភស្តុតាងគ្រប់ជ្រុងជ្រោយ និងអាចជឿជាក់បាន។ នៅពេលឆ្លើយតបទៅនឹងមូលដ្ឋានទី៦ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងដោយមានកំហុសថាសំអាងហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល ធ្វើឡើងត្រឹមត្រូវ និងមានភស្តុតាងគាំទ្រគ្រប់គ្រាន់ ។ ចំពោះមូលដ្ឋានទី ៧ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានឆ្លើយតបទៅនឹងកំហុសអង្គហេតុ និងអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពាក់ព័ន្ធនឹងភាពធ្ងន់ធ្ងរនៃឧក្រិដ្ឋកម្មដែលបានចោទប្រកាន់។ នៅពេលឆ្លើយតបទៅនឹងមូលដ្ឋានទី ៨ ដល់ ទី១៧ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានតវ៉ាលើកំហុសពាក់ព័ន្ធនឹងការអនុវត្ត និងការបកស្រាយច្បាប់ ដែលធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។ ចំណុចចុងក្រោយ ចំពោះមូលដ្ឋានទី១៨ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ មិនអើពើទឡ្ហីករណ៍របស់មេធាវីការពារក្តី ដែលលើកឡើងថា សិទ្ធិទទួលបានជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន ត្រូវបានរំលោភបំពានដោយមិនអាចជួសជុលបាននៅក្នុងកិច្ចដំណើរការនីតិវិធី ហើយ *ផលប៉ះពាល់រួមគ្នា(cumulative impact)*នៃការរំលោភបំពានទាំងនេះធ្វើឲ្យខូច

[6] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ឯកសារ D360 ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

ខាតភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ដែលពុំអាចឱ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌។

4. អាស្រ័យហេតុនេះ មេធាវីការពារក្ដីសូមគោរពស្នើសុំឱ្យ អង្គបុរេជំនុំជម្រះ ទទួលយក និងយល់ព្រមតាម *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* ទាំងស្រុង (ហើយតម្កល់*ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន* (“*ដីកាសម្រេចលើកលែងការចោទប្រកាន់*”)[7]។

## ទឡ្ហីករណ៍នៅក្នុងការឆ្លើយតប

5. ដោយសារការកម្រិតចំនួនទំព័រ និងពេលវេលា មេធាវីការពារក្ដីនឹងឆ្លើយតបតែចំពោះទឡ្ហីករណ៍ទាំងឡាយណានៅក្នុងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលប៉ះពាល់ខ្លាំងបំផុតចំពោះលទ្ធផលនៃ*បណ្ដឹងឧទ្ធរណ៍របស់ អោ អាន*។ ទោះបីជាយ៉ាងនេះក្ដី ការខកខានមិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ផ្សេងទៀតរបស់សហព្រះរាជអាជ្ញាអន្តរជាតិមិនគួរបកស្រាយថាជាព្រមទទួលយកដោយស្ងៀមស្ងាត់នោះទេ ហើយទឡ្ហីករណ៍របស់មេធាវីការពារក្ដីនៅក្នុងការឆ្លើយតបនេះពុំមានព្យសនកម្មចំពោះទឡ្ហីករណ៍ទាំងឡាយដែលលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍នោះទេ។

## I. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះមូលដ្ឋានទី១ នៃបណ្ដឹងឧទ្ធរណ៍ ÷ ច្បាប់ពាក់ព័ន្ធពុំអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដោយឡែកពីគ្នា និងកំណត់ថា ដីកាលើកលែងការចោទប្រកាន់ ត្រូវអនុវត្ត។

6. សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានតវ៉ាទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្ដីដែលថាការចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នានៅក្នុងរឿងក្ដីតែមួយ គឺជាកំហុសអង្គច្បាប់ ហើយមានភាពអយុត្តិធម៌ជាមូលដ្ឋានទេ[8]។ ផ្ទុយទៅវិញ យោងតាមសំអាងហេតុដែលបានលើកឡើងនៅក្នុង*បណ្ដឹងឧទ្ធរណ៍របស់ អោ អាន*[9] និងនៅក្នុងចំណុចខាងក្រោម ច្បាប់ជាធរមានពុំអនុញ្ញាតឱ្យចេញដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នានោះទេ ហើយ

---

[7] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន* (“ដីកាសម្រេចលើកលែងការចោទប្រកាន់”) ឯកសារ D359 ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨។

[8] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥-១៥។

[9] *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២០-៣២។

កំណត់ថា *ដីកាលើកលែងការចោទប្រកាន់* ត្រូវអនុវត្ត។

## ក. ទឡ្ហីករណ៍លើខ្លឹមសារអត្ថបទ

7. សហព្រះរាជអាជ្ញាអន្តរជាតិ ផ្ដល់ទឡ្ហីករណ៍តវ៉ាថា ការណែនាំស្រពិចស្រពិលនៅក្នុងវិធាន ៦៧ ជាភាសាអង់គ្លេសថា សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាដំណោះស្រាយតែ*មួយ* អាចជាការចោទប្រកាន់បញ្ជូនជនត្រូវចោទទៅជំនុំជម្រះ ឬលើកលែងការចោទប្រកាន់លើរឿងក្ដី មិនគួរយកមកពិចារណានោះទេ ដោយសារ "វិធាននេះជាភាសាខ្មែរមិនបានប្រើពាក្យ "សហចៅក្រមស៊ើបអង្កេត" ជាពហុវចនៈទេ និងអាចសំដៅទៅសហចៅក្រមស៊ើបអង្កេតតែម្នាក់ ឬ ទាំងពីរ"[10]។ សហព្រះរាជអាជ្ញាអន្តរជាតិ ផ្ដល់ទឡ្ហីករណ៍បន្ថែម ដោយយោងលើវិធាន ១(២) ថា វិធានផ្ទៃក្នុងអនុញ្ញាតឲ្យដីកាដំណោះស្រាយអាចចុះហត្ថលេខាដោយ សហចៅក្រមស៊ើបអង្កេត តែម្នាក់ឯងបាន[11]។

8. សហព្រះរាជអាជ្ញាអន្តរជាតិ កំពុងព្យាយាមគេចពីខ្លឹមសារសំខាន់នៃទឡ្ហីករណ៍របស់ អោ អាន គឺវិធាន ៦៧ ដែលអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយតែមួយ។ ដីកាដំណោះស្រាយដោយ សហចៅក្រមស៊ើបអង្កេត តែម្នាក់ អាចធ្វើទៅបានអនុលោមតាមវិធានផ្ទៃក្នុង នៅពេលការខ្វែងយោបល់គ្នារវាង សហចៅក្រមស៊ើបអង្កេត ទាំងពីរត្រូវបានដោះស្រាយរួចរាល់ដោយ អង្គបុរេជំនុំជម្រះ អនុលោមតាមវិធាន ៧២។ ផ្ទុយពីការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ អ្វីដែលមិនអនុញ្ញាតនោះគឺករណី "សហចៅក្រមស៊ើបអង្កេត ម្នាក់ៗចេញដីកាដំណោះស្រាយ រៀងៗខ្លួន"[12]។ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានផ្ដល់យុត្តិកម្មដែលអាចជឿជាក់បានចំពោះការបកស្រាយវិធាន ៦៧ លើករណីនេះទេ។ តាមពិត ទឡ្ហីករណ៍របស់គាត់ថា ពាក្យ "អាចជា" និង "ឬ" នៅក្នុងវិធាន ៦៧ "គ្រាន់តែជាការលើកឡើងអំពីលក្ខខណ្ឌតម្រូវថា ដីកាដំណោះស្រាយមួយដែលសម្រេចសេចក្ដីលើគ្រប់អង្គហេតុ និងបទចោទទាំងអស់នៅចំពោះមុខសហចៅក្រមស៊ើបអង្កេតណាម្នាក់ ឬ សហចៅក្រមស៊ើបអង្កេតផ្សេងៗតែប៉ុណ្ណោះ"[13] មិនអាចយកជាការបានទេ។

[10] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៨។

[11] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៨។

[12] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩។

[13] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩។

វាជាការពុំសមហេតុផលទេនៅក្នុងការតវ៉ាថា ដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា ប៉ុន្តែមានសុពលភាពដូចគ្នា បង្ហាញយ៉ាងសមស្របអំពីអង្គហេតុ និងបទចោទ និង "សន្និដ្ឋានទៅលើរឿងក្ដីមួយច្បាស់លាស់"[14]។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងដីកាលើកលែងការចោទប្រកាន់ដែលមានសុពលភាពនៅក្នុងរឿងក្ដីតែមួយមិនមែនជាសេចក្ដីសម្រេចស្ថាពរនោះទេ។

9. សហព្រះរាជអាជ្ញាអន្តរជាតិ បន្តបកស្រាយដោយភាន់ច្រឡំសាជាថ្មីចំពោះ *សេចក្ដីសម្រេច* របស់អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") នៅក្នុងសំណុំរឿង ០០១ ថាជាការបញ្ជាក់យ៉ាងច្បាស់លាស់លើសុពលភាពនៃដីកាដំណោះស្រាយដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នាចំនួនពីរ អនុលោមតាមវិធាន ៦៧[15]។ ឃ្លាអនុវត្តនៅក្នុងអត្ថបទដែលបានដកស្រង់គឺ "ស្នើឲ្យចេញ"[16]។ ដូចបានតវ៉ានៅក្នុង*ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ* អង្គជំនុំជម្រះតុលាការកំពូលពុំបានគិតទុកជាមុនអំពីសុពលភាព និងដីកាដំណោះស្រាយចំនួនពីរ ដែលផ្ទុយគ្នា អនុលោមតាមវិធាន ៦៧ នោះទេ ប៉ុន្តែ បានពិនិត្យមើលការអនុវត្តនីតិវិធីខ្វែង

---

[14] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩។

[15] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០។

[16] សំណុំរឿង ០០១/១៨-០៧-២០០៧-អវតក/អជតក *សាលដីកា* ("*សាលដីកាលើសំណុំរឿង ០០១*") ឯកសារ F28 ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៥ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី១ (ដែលសម្រេចថា "តួនាទីរបស់អង្គបុរេជំនុំជម្រះនៅក្នុងការដោះស្រាយករណីខ្វែងយោបល់គ្នារវាងសហព្រះរាជអាជ្ញាទាំងពីររូប ឬ រវាងសហចៅក្រមស៊ើបអង្កេតទាំងពីររូប ពុំបានធ្វើឲ្យមានការកែប្រែដល់សេចក្ដីសន្និដ្ឋានថា ពាក្យពេចន៍ "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នេះ មិនមែនជាលក្ខខណ្ឌតម្រូវផ្នែកយុត្តាធិការរបស់ អ.វ.ត.ក នោះទេ។ ក្នុងករណីដែលមានការខ្វែងយោបល់គ្នានៅក្នុងវិធាន ៧១ ឬ ៧២ នៃវិធានផ្ទៃក្នុង នៅពេលដែលមានការខ្វែងយោបល់គ្នានេះស្ដីពីបញ្ហាកិច្ចប្រតិបត្តិការ ការចេញសេចក្ដីសម្រេច ឬ ការចេញដីកា ដោយសារមូលហេតុថាតើជនសង្ស័យ ឬ ជនត្រូវចោទ គឺជា "មេដឹកនាំជាន់ខ្ពស់" ឬជា "អ្នកទទួលខុសត្រូវខ្ពស់បំផុត" ដែរ ឬយ៉ាងណានោះ តួនាទីរបស់អង្គបុរេជំនុំជម្រះនឹងត្រូវសម្រេចពីបញ្ហាខ្វែងគំនិតគ្នារបស់សហព្រះរាជអាជ្ញា ឬ សហចៅក្រមស៊ើបអង្កេត។ ឧទាហរណ៍ ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា សហចៅក្រមស៊ើបអង្កេតណាមួយមានកំហុសក្នុងការសម្រេចចេញ ឬ ក្នុងការស្នើឲ្យចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬ ដីកាលើកលែងការចោទប្រកាន់ដោយមូលហេតុថា ជនត្រូវចោទ គឺជា ឬ មិនមែនជាជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុត ហើយប្រសិនបើ អង្គបុរេជំនុំជម្រះមិនអាចទទួលបានសម្លេងគាំទ្រភាគច្រើនលើសលប់ទៅលើផលវិបាកនៃសេណារីយ៉ូនោះទេ "ដំណើរការស៊ើបអង្កេតត្រូវបន្តទៅមុខ"")។

យោបល់គ្នានៃ អ.វ.ត.ក អនុលោមតាមវិធាន ៧២[17]។

## ខ. ទឡ្ហីករណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌

10. បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិ លើកទឡ្ហីករណ៍ថា ដីកាដំណោះស្រាយចំនួនពីរដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នាពុំរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន នោះទេ[18]។ ទឡ្ហីករណ៍នេះមិនគួរឲ្យជឿជាក់នោះទេ ហើយនៅពេលវិភាគឲ្យបានលម្អិត វាគាំទ្រទឡ្ហីករណ៍របស់មេធាវីការពារក្តី មិនមែនធ្វើឲ្យទឡ្ហីករណ៍ទាំងនេះចុះខ្សោយនោះទេ។

11. ចំណុចទី១ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើឡើងថា ដីកាដំណោះស្រាយផ្ទុយគ្នា ដែលពុំធ្លាប់មានពីមុនមក ពុំមែនអយុត្តិធម៌នោះទេ ដោយសារតែ "រចនាសម្ព័ន្ធពិសេសប្លែកពីគេ" ពាក់ព័ន្ធនឹងសហចៅក្រមស៊ើបអង្កេតពីររូប ដែលត្រូវបាន "ចរចា" និងអនុម័ត បន្ទាប់ពីមានការពិភាក្សាគ្នាយ៉ាងល្អិតល្អន់ដោយភាគីនានា ដែលបានប្តេជ្ញាលើកស្ទួយ "បទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវយុត្តិធម៌ និងដំណើរការច្បាប់ត្រឹមត្រូវ"[19]។ តាំងពីដំបូង សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងខុសតែម្តង។ ការតែងតាំងចៅក្រមស៊ើប ពីររូបនៅក្នុងរឿងក្តីតែមួយពុំមែន "មានលក្ខណៈពិសេស" ចំពោះ អ.វ.ត.ក នោះទេ។ អ្វីដែលពិសេសនោះគឺការចេញដីកាដំណោះស្រាយពីរដែលផ្ទុយគ្នា និងដោយឡែកពីគ្នា។ ឧទាហរណ៍ នៅក្នុងប្រទេសបារាំង ចំពោះរឿងក្តីស្មុគស្មាញ ជាពិសេស រឿងក្តីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មអន្តរជាតិ ចៅក្រមស៊ើបអង្កេតអន្តរជាតិពីររូបអាចត្រូវបានចាត់តាំងលើរឿងក្តីបែបនោះ[20]។ ចៅក្រមម្នាក់អាចមិនយល់ស្របជាមួយនឹងចៅក្រមម្នាក់ទៀត ហើយមិនព្រមចុះហត្ថលេខាលើដីកាដំណោះស្រាយ ដែលជាមូលដ្ឋាននៃបណ្តឹងឧទ្ធរណ៍សម្រាប់ភា

---

[17] សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/អបជ៦០ *ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាសម្រេចលើកលែងការចោទប្រកាន់ អោ អាន* ("*ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ*") ឯកសារ D359/3/4 ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៩ កថាខណ្ឌ ៦៦។

[18] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១-១៣។

[19] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១។

[20] នៅបារាំង ចៅក្រមស៊ើបអង្កេតពីររូបអាចចាត់តាំងលើរឿងក្តីតែមួយ ប៉ុន្តែចៅក្រមមួយរូបទទួលបន្ទុក និងត្រូវចុះហត្ថលេខាលើដីកាដំណោះស្រាយ អាចជា ដីកាលើកលែងការចោទប្រកាន់ ឬ ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ មិនថាវិធាននីតិវិធីបារាំងកំណត់ទំនាក់ទំនងរវាងចៅក្រមស៊ើបអង្កេតទាំងពីរយ៉ាងដូចម្តេចនោះទេ លទ្ធផលគួរឲ្យកត់សម្គាល់គឺការចេញដីកាដំណោះស្រាយតែមួយគត់។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨៣-១, ៨៣-២ (បារាំង) ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី២។

គឺនៃកិច្ចដំណើរការនីតិវិធី ប៉ុន្តែ ចៅក្រមមិនអាចចេញដីកាដែលផ្ទុយគ្នានោះទេ[21]។ ការដែលមាននីតិវិធីពិសេសមួយស្តីពីការខ្វែងយោបល់គ្នានៅក្នុងមាត្រា ៧ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងព្រះរាជាណាចក្រកម្ពុជា និងវិធាន ៧២ បង្ហាញថា ភាគីមិនដែលគិតគូរអំពីលទ្ធភាពអាចចេញដីកាដំណោះស្រាយដែលផ្ទុយគ្នានៅក្នុងរឿងក្តីតែមួយនោះទេ។

12. ម្យ៉ាងវិញទៀត គ្រាន់តែអ្នកធ្វើសេចក្តីព្រាងប៉ុនប៉ងធ្វើឱ្យស្របតាមបទដ្ឋានអន្តរជាតិ ពុំមែនរារាំងតុលាការនេះ ដោយស្វ័យប្រវត្តិ មិនឱ្យធ្វើបណ្តឹងណាមួយ ឬ បណ្តឹងទាំងអស់ អំពីភាពមិនយុត្តិធម៌កើតចេញពីវចនាសម្ព័ន្ធ ការបកស្រាយ ឬ ការអនុវត្តវិធានជាធរមាន ឬ បញ្ហាផ្សេងទៀតនោះទេ[22]។ ចំណុចត្រូវពិនិត្យ និងដោះស្រាយឱ្យបានល្អិតល្អន់គឺឰសនកម្មដែលបានបង្កដាក់ស្តែងដោយដីកាដំណោះស្រាយដែលផ្ទុយគ្នា រំលោភដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន

[21] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៨៣-១ កថាខណ្ឌ ១ (បារាំង) ('Lorsque la gravité ou la complexité de l'affaire le justifie, l'information peut faire l'objet d'une cosaisine selon les modalités prévues par le présent article')។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៧៩, ១៨៦-៣ ('Lorsque l'information a fait l'objet d'une cosaisine, elles peuvent également, en l'absence de cosignature par les juges d'instruction cosaisis conformément à l'article 83-2, interjeter appel de ces ordonnances.') ៦២៨, ៦២៨-១ (បារាំង)។ តុលាការកំពូលផ្នែកព្រហ្មទណ្ឌ n°14-83443 ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៤ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៣។ តុលាការកំពូលផ្នែកព្រហ្មទណ្ឌ លេខ 15-81585 ថ្ងៃទី២ ខែមិថុនា ឆ្នាំ ២០១៥ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៤។ *សូមមើល* LexisNexis, 'Fasc. 15: Chambre de l'instruction. – Pouvoirs du président', *LexisNexis JurisClasseur Procédure Pénale* (2018) កថាខណ្ឌ ៤៤ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៥ ('[I]l est également possible, et ce depuis l'entrée en vigueur de la loi n° 2007-291 du 5 mars 2007, lorsque l'information a fait l'objet d'une cosaisine et que l'ordonnance de renvoi n'est pas signée par tous les juges, ce qui peut laisser supposer un désaccord entre eux.')។

[22] រឿងក្តី *ព្រះរាជអាជ្ញា ទល់នឹង* *Duško Tadić* រឿងក្តីលេខ IT-94-1 *សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្នើសុំបណ្តឹងឧទ្ធរណ៍បន្ទាន់បន្តស្តីពីយុត្តាធិការ* ចុះថ្ងៃទី២ ខែតុលា ឆ្នាំ១៩៩៥ កថាខណ្ឌ ៤៥ ដែលដាក់ភ្ជាប់ជាពាក្យសុំទី៦ (សម្រេច "លក្ខខណ្ឌថា សាលាក្តីអន្តរជាតិ "បង្កើតឡើងដោយច្បាប់" គឺថា ការបង្កើតសាលាក្តីនេះត្រូវធ្វើឡើងស្របតាមវិធានច្បាប់ [...] ដើម្បីឱ្យសាលាក្តីបែបនេះត្រូវបង្កើតឡើងស្របតាមវិធានច្បាប់ ទាល់តែបង្កើតឡើងស្របតាមបទដ្ឋានអន្តរជាតិត្រឹមត្រូវ។ សាលាក្តីនេះត្រូវធានានូវភាពត្រឹមត្រូវ យុត្តិធម៌ និងដោយអព្យាក្រឹត្យ ស្របទាំងស្រុងទៅនឹងលិខិតុបករណ៍សិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ដោយអន្តរជាតិ")។ រឿងក្តី *វដ្តអាជ្ញា ទល់នឹង* *Kanyabashi* រឿងក្តីលេខ ICTY-96-15-T *សេចក្តីសម្រេចលើញត្តិរបស់មេធាវីការពារក្តីស្តីពីយុត្តាធិការ* ចុះថ្ងៃទី១៨ ខែមិថុនា ឆ្នាំ១៩៩៧ កថាខណ្ឌ ៤៣ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៧ (ដែលសម្រេចថា "សាលាក្តីនេះក៏យល់ស្របនឹងការយល់ឃើញដែលបានលើឡើងដោយអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៅក្នុងរឿងក្តី Tadić ដែលបញ្ជាក់ថា នៅពេលសម្រេចថាតើសាលាក្តីត្រូវបាន "បង្កើតឡើងតាមច្បាប់" ដែរឬទេ គេគួរពិចារណាបង្កើតស្ថាប័នមួយដែលស្របតាមបទដ្ឋានអន្តរជាតិត្រឹមត្រូវ ដែលផ្តល់ការធានាគ្រប់បែបយ៉ាងដល់ភាពយុត្តិធម៌ និងត្រឹមត្រូវ"។

ពុំមែនចេតនារបស់អ្នកចរចានោះទេ។

13. ចំណុចទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់ដោយពុំមានភ័ស្តុតាងសំអាងថា ការិយាល័យសហព្រះរាជអាជ្ញាពុំមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាងចំពោះដីកាបញ្ជូនរឿងទៅជំនុំជម្រះ ហើយ "ការចេញដីកាសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះដោយ សហចៅក្រមស៊ើបអង្កេត មួយរូប មិនបានដកចេញសច្ចធារណ៍នៃនិរទោសទេ"[23]។ ចំពោះផ្នែកទី១ សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងខុស។ នៅ អ.វ.ត.ក ការិយាល័យសហព្រះរាជអាជ្ញាមាន *បន្ទុកក្នុងការបង្ហាញភ័ស្តុតាង* ចាប់តាំងពីពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ រហូតដល់ដំណាក់កាលបណ្តឹងសាទុក្ខចុងក្រោយ ហើយនឹងនៅគ្រប់ដំណាក់កាលនីតិវិធី ចំពោះតែនៅពេល *បទដ្ឋាននៃការបង្ហាញភ័ស្តុតាង* ផ្លាស់ប្តូរ[24]។ ដូច្នេះ ដើម្បីអាចឲ្យ សហចៅក្រមស៊ើបអង្កេត ចោទប្រកាន់ អោ អាន ទៅជំនុំ

---

[23] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១២។

[24] ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣៧ (បារាំង) (ដែលលើកឡើងថា "ជនត្រូវចោទទាំងអស់ (បុគ្គលស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) ត្រូវសន្មតជាជនគ្មានទោស")។ រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង* *Bemba Gombo* រឿងក្តីលេខ ICC-01/05-01/08 *សេចក្តីសម្រេចអនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីបទចោទរបស់រដ្ឋអាជ្ញាប្រឆាំងនឹង* *Jean-Pierre Bemba Gombo* ("*សេចក្តីសម្រេចលើបទចោទ Bemba*") ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០០៩ កថាខណ្ឌ ២៧ ៣១ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៨ (ដែលសម្រេចថា "អ្នកធ្វើសេចក្តីព្រាងលក្ខន្តិកៈដែលបានបង្កើតបទដ្ឋានភ័ស្តុតាងខ្ពស់ចំនួនបីផ្សេងគ្នាសម្រាប់ដំណាក់កាលនីតិវិធីនីមួយៗអនុលោមតាមមាត្រា ៥៨(១) ៦១(៧) និង ៦៦(៣) នៃលក្ខន្តិកៈ។ លក្ខណៈនៃបទដ្ឋានភ័ស្តុតាងទាំងនេះអាស្រ័យលើដំណាក់កាលនីតិវិធីខុសៗគ្នា ហើយក៏ស្របជាមួយនឹងផលប៉ះពាល់ដែលអាចប្រមើលមើលឃើញនៃសេចក្តីសម្រេចពាក់ព័ន្ធស្តីពីសិទ្ធិមនុស្សជាមូលដ្ឋានរបស់ជនដែលត្រូវបានចោទប្រកាន់ [...] នៅពេលធ្វើសេចក្តីសម្រេច អង្គជំនុំជម្រះសូមគូសបញ្ជាក់ថា អង្គជំនុំជម្រះគោរពតាមគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* ដែលជាសមាសធាតុនៃសច្ចធារណ៍និរទោស ពោលគឺ វាជាគោលការណ៍ទូទៅមួយនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ដែលត្រូវអនុវត្តដូចគ្នានៅគ្រប់ដំណាក់កាលនីតិវិធី រួមទាំងដំណាក់កាលមុនអង្គសេចក្តី"។ គណៈកម្មាធិការសិទ្ធិមនុស្សអន្តរជាតិ *លិខិតលេខ 1620/2007*, CCPR/C/101/D/1620/2007/Rev.2 (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១) កថាខណ្ឌ ៩.៦ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី៩ (ក្នុងករណីតុលាការជាតិត្រូវបានរកឃើញថារំលោភសច្ចធារណ៍និរទោសដោយច្រានចោលបន្ទុកនៃការបង្ហាញភ័ស្តុតាងមិនមានភាពសមាមាត្រ ចំពោះជនជាប់ចោទ នៅក្នុងអំឡុងពេលសវនាការបឋម)។ រឿងក្តី *Telfner* ទល់នឹង*ប្រទេសអូទ្រីស* តុលាការសិទ្ធិមនុស្សអឺរ៉ុប ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០១ កថាខណ្ឌ ១៨ ដែលបានដាក់ភ្ជាប់ជាពាក្យសុំទី១០ (ពិភាក្សាអំពីនីតិវិធីមុនអង្គសេចក្តីនៅក្នុងរឿងក្តីព្រហ្មទណ្ឌ តុលាការបានសម្រេចថា "នៅពេលតម្រូវឲ្យអ្នកដាក់ពាក្យសុំផ្តល់ការពន្យល់ទោះបីពួកគេពុំអាចបង្ហាញរឿងក្តីជាបឋមអាចឲ្យជឿជាក់បានប្រឆាំងនឹងខ្លួនក៏ដោយ តុលាការបានបង្វែងបន្ទុកនៃការបង្ហាញភ័ស្តុតាងពីអយ្យការមកឲ្យខាងមេធាវីការពារក្តីវិញ")។

ជម្រះបាន *ការិយាល័យសហព្រះរាជអាជ្ញាត្រូវបង្ហាញ* តាមរយៈដីកាសន្និដ្ឋានស្ថាពរអនុលោមតាម វិធាន ៦៦(៦) (បន្ទុកនៃការបង្ហាញភ័ស្តុតាង) ថា ភ័ស្តុតាងនៅក្នុងសំណុំរឿង "មានលក្ខណៈធ្ងន់ធ្ងរ និងស៊ីសង្វាក់គ្រប់គ្រាន់ បង្ហាញនូវអានុភាពនៃតម្លៃភ័ស្តុតាងមួយជាក់លាក់" (បទដ្ឋាននៃការបង្ហាញភ័ស្តុតាង)។ ការលើកឡើងខុសពីនេះគឺធ្វើឱ្យសច្ចធារណ៍និរទោសរបស់ អោ អាន គ្មានន័យ។ ចំពោះទឡ្ហីករណ៍ផ្នែកក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ បានគេចវេស គឺ ការរំលោភបំពានពុំមែនស្ថិតត្រង់ចំនួនហត្ថលេខាចុះលើដីកាបញ្ជូនរឿងទៅជំនុំជម្រះនោះទេ ប៉ុន្តែវាស្ថិតនៅត្រង់អត្ថិភាពនៃដីកាលើកលែងការចោទប្រកាន់ដែលមានសុពលភាព។ ការបញ្ជូន អោ អាន ទៅជំនុំជម្រះ បើទោះជាមាន*ដីកាលើកលែងការចោទប្រកាន់* រួចហើយនោះ គឺជាការរំលោភធ្ងន់ធ្ងរលើសច្ចធារណ៍និរទោស និងគោលការណ៍*វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* រួមជាមួយនឹងការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌មួយចំនួនផ្សេងទៀត (ដែលបានលើកឡើងដោយមេធាវីការពារក្តីនៅក្នុងបណ្តឹងឧទ្ធរណ៍) ដែល សហព្រះរាជអាជ្ញាអន្តរជាតិ មិនខ្វល់នឹងពិចារណានៅក្នុងចម្លើយតបរបស់ខ្លួន តាមការសន្មត គឺដោយសារគាត់យល់ស្របជាមួយនឹងចំណុចទាំងនេះ[25]។

14. ចំណុចទី៣ សហព្រះរាជអាជ្ញាអន្តរជាតិ បញ្ជាក់ការអះអាងដោយមានកំហុសរបស់ខ្លួនសាជាថ្មីថា ការខកខានរបស់ អង្គបុរេជំនុំជម្រះ មិនអាចរកសម្លេងភាគច្រើនលើសលប់លើបណ្តឹងឧទ្ធរណ៍ទាំងនេះនឹងបើកលទ្ធភាពឱ្យបញ្ជូនរឿងក្តីនេះទៅជំនុំជម្រះ[26]។ មេធាវីការពារក្តីបានឆ្លើយតបទៅនឹងការបកស្រាយមិនត្រឹមត្រូវរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ លើកិច្ចព្រមព្រៀងរវាង អ.ស.ប និងកម្ពុជា យុត្តិសាស្ត្ររបស់អង្គជំនុំជម្រះតុលាការកំពូល និងវិធានផ្ទៃក្នុងត្រង់ចំណុចនេះ។ ដូច្នេះ មេធាវីការពារក្តីសូមដាក់បញ្ចូល និងយោងការឆ្លើយតបនោះនៅក្នុងនេះតែម្តង[27]។

## គ. ដំណោះស្រាយ

[25] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២៨-៣៥ (រៀបរាប់អំពីសិទ្ធិទទួលបានការជំនុំជម្រះដោយសាលាក្តីមានសមត្ថកិច្ច និងយុត្តិធម៌ សិទ្ធិទទួលបានការជូនដំណឹងភ្លាមៗ និងលម្អិតអំពីលក្ខណៈ និងមូលហេតុនៃបទចោទប្រឆាំងនឹងខ្លួន សិទ្ធិទទួលបានការជំនុំជម្រះដោយគ្មានការពន្យារពេលដោយមិនសមហេតុផល គោលការណ៍នីត្យានុកូលភាព និង *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ*)។

[26] *ចម្លើយតបរបស់ ស.ព.អ* កថាខណ្ឌ ១៣។

[27] *ចម្លើយតបរបស់ អោ អាន ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦៣-៦៧។

15. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា អោ អាន កំពុងព្យាយាមរក "ដំណោះស្រាយតាមទំនើងចិត្ត និងមិនមានគោលការណ៍ចំពោះភាពផ្ទុយគ្នានៃដីកាដំណោះស្រាយ"[28]។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានស្នើសុំ អង្គបុរេជំនុំជម្រះ ដោះស្រាយស្ថានភាពមិនយុត្តិធម៌នេះដោយអនុវត្តវិធានជាធរមាន។ យោងតាមសំអាងហេតុដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍នេះ មេធាវីការពារក្តីស្នើសុំ អង្គបុរេជំនុំជម្រះ ឲ្យសម្រេចថា ក្របខ័ណ្ឌច្បាប់នៃ អ.វ.ត.ក និងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("*កតិកាសញ្ញាអន្តរជាតិ*") ពុំអនុញ្ញាតឲ្យចេញដីកាដំណោះស្រាយដែលផ្ទុយគ្នានៅក្នុងរឿងក្តីតែមួយនោះទេ។ យោងតាមមាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញកម្ពុជា វិធាន ២១(១) និងយុត្តិសាស្ត្រអន្តរជាតិជាធរមាន[29] វិមតិសង្ស័យនៅក្នុងដំណាក់កាលណាមួយនៃកិច្ចដំណើរការនីតិវិធីត្រូវបានសម្រេចជាប្រយោជន៍ដល់ អោ អាន។ ដូច្នេះ *ដីកាលើកលែងការចោទប្រកាន់*ត្រូវអនុវត្ត។

16. ចំពោះ សហព្រះរាជអាជ្ញាអន្តរជាតិ គាត់ស្នើសុំឲ្យផ្តល់អាទិភាពលើដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាជាងដីកាលើកលែងការចោទប្រកាន់របស់ សហចៅក្រមស៊ើបអង្កេតជាតិ ដោយរំលោភលើសមភាពរវាងចៅក្រម អនុលោមតាមវិធាន (វិធាន ៧៧(១៣)(ខ)) ដែលពុំកំណត់ជាក់លាក់ ឬ ដោយប្រយោលចំពោះការចេញដីកាសម្រេចចំនួនពីរដែលផ្ទុយគ្នា និងដាច់ដោយឡែកពីគ្នា និងយុត្តិសាស្ត្រដែលបានដកស្រង់ដែលពុំអនុវត្តចំពោះរឿងក្តីបច្ចុប្បន្ន។ អ្វីដែលសំខាន់ សហព្រះរាជអាជ្ញាអន្តរជាតិ ស្នើសុំអង្គបុរេជំនុំជម្រះ ឲ្យបំភ្លៃវិធានជាធរមាន ដើម្បីផ្តល់យុត្តិកម្មលើការរំលោភជាក់ស្តែងលើសិទ្ធិជាមូលដ្ឋានរបស់ អោ អាន។

## II. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះមូលដ្ឋានទី៣ នៃបណ្តឹងឧទ្ធរណ៍÷ សហព្រះរាជអាជ្ញាអន្តរជាតិ ជ្រើសរើសតាមអំពើចិត្តចំពោះផ្នែកនៃប្រវត្តិចរចា ដើម្បីព្យាយាមពង្រីកយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក

17. សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញទឡ្ហីករណ៍ថា មេធាវីការពារក្តី (ក) យល់មិនត្រឹមត្រូវលើប្រវត្តិនៃការចរចា និង (ខ) បកស្រាយមិនត្រឹមត្រូវលើលក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃលើ

---

[28] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១៤-១៥។

[29] *Bemba* សេចក្តីសម្រេចលើបទចោទ កថាខណ្ឌ ៣១។

"ការទទួលខុសត្រូវខ្ពស់បំផុត"[30]។ ទោះបីជាយ៉ាងនេះក្តី សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានផ្តល់មូលដ្ឋានសំអាងលើទឡ្ហីករណ៍ទាំងនេះ ហើយបែរជាជ្រើសរើសតាមអំពើចិត្តក្នុងផ្នែកនៃប្រវត្តិចរចា ដើម្បីព្យាយាមពង្រីកយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក ហើយគាត់ខកខានមិនបានពិចារណាលើទឡ្ហីករណ៍របស់មេធាវីការពារក្តី ប្រកបដោយអត្ថន័យ។

18. ចំណុចទី១ មេធាវីការពារក្តីពុំពិចារណាលើប្រភេទ "ការទទួលខុសត្រូវខ្ពស់បំផុត" ដូចបានអះអាងដោយ សហព្រះរាជអាជ្ញាអន្តរជាតិ[31]។ ផ្ទុយទៅវិញ មេធាវីការពារក្តីបង្ហាញទឡ្ហីករណ៍យ៉ាងច្បាស់ ហើយបានពិនិត្យលម្អិតលើប្រវត្តិចរចា ដែលបង្ហាញថា (ក) ពាក្យ "មេដឹកនាំ" ត្រូវបានកម្រិតត្រឹមថ្នាក់ដឹកនាំកំពូលរបស់បក្សកុម្មុយនីស្តកម្ពុជា និង (ខ) ប្រភេទ "ទទួលខុសត្រូវខ្ពស់បំផុត" ក្រោយមក បានពង្រីកយុត្តាធិការរបស់តុលាការក្នុងការចោទប្រកាន់ ឌុច ប៉ុន្តែ ពុំមានចេតនាបង្កើតជាប្រភេទគ្រប់ទាំងអស់នោះទេ[32]។ ផ្ទុយមកវិញ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ ដកស្រង់តែសុន្ទរកថានយោបាយរបស់ឧប នាយករដ្ឋមន្ត្រី សុខ អាន នៅចំពោះមុខរដ្ឋសភាជាតិកម្ពុជា[33] ហើយគាត់មិនពិចារណាសេចក្តីថ្លែងការណ៍របស់ភាគីធ្វើឡើងនៅក្នុងអំឡុងពេលនៃដំណើរការចរចានោះទេ[34]។ ដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានផ្តល់ជាមូលដ្ឋានចំពោះការស្នើសុំ "ការច្រានចោលដោយពុំចាំបាច់ពិចារណាវែងឆ្ងាយ" នៃទឡ្ហីករណ៍របស់មេធាវីការពារក្តីនោះទេ[35]។

19. ចំណុចទី២ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានគាំទ្រការអះអាងរបស់គាត់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុវត្តគោលការណ៍ *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ* និងការបកស្រាយតឹងរ៉ឹង នៅពេលសម្រេចលើដែនកំណត់នៃប្រភេទ "ទទួលខុសត្រូវ

[30] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២០។

[31] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២១។

[32] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៤៦-៤៧ ៥៣-៥៤។ សំណុំរឿងលេខ ០០៤/២/០៧-០៩-២០០៩-អវតក/កសចស *ចម្លើយតបរបស់ អោ អាន ទៅនឹងដីកាសន្និដ្ឋានរបស់សហព្រះរាអាជ្ញា អនុលោមតាមវិធាន ៦៦* ("*ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ*") ឯកសារ **D351/6** ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០១៧ កថាខណ្ឌ ៨២-៩២។

[33] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៣ លេខយោងជើងទំព័រ ៣៣។

[34] *ចម្លើយតបទៅនឹងដីកាសន្និដ្ឋានស្ថាពរ* កថាខណ្ឌ ៨៧។

[35] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៤។

ខ្ពស់បំផុត"[36]។ មេធាវីការពារក្ដីនៅតែរក្សាជំហរដដែលផ្អែកតាមទឡ្ហីករណ៍របស់ខ្លួននៅក្នុងបណ្ដឹងឧទ្ធរណ៍ ហើយ សហព្រះរាជអាជ្ញាអន្តរជាតិ បានពន្យល់តិចតួច ស្ទើរតែគ្មានតែម្ដងអំពីវិធីដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ "ធ្វើការបកស្រាយក្នុងន័យចង្អៀត" លើប្រភេទទទួលខុសត្រូវខ្ពស់បំផុត ដូចបានចោទប្រកាន់[37]។

20. ចំណុចទី៣ សហព្រះរាជអាជ្ញាអន្តរជាតិ យល់ខុសចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្ដីអំពីវិធីសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ច្របាច់បញ្ចូលទស្សនទានយុត្តាធិការបុគ្គលជាមួយនឹងសហឧក្រិដ្ឋកម្មរួម ហើយគាត់អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកាតព្វកិច្ចពិនិត្យមើលទម្រង់នៃការទទួលខុសត្រូវមួយនេះនៅពេលវាយតម្លៃថាតើ អោ អាន ស្ថិតនៅក្នុងវិសាលភាពនៃយុត្តាធិការបុគ្គល[38]។ មេធាវីការពារក្ដីយល់ស្របថា ការទទួលខុសត្រូវព្រហ្មទណ្ឌអាចជាកត្តាមួយនៅក្នុងការកំណត់យុត្តាធិការបុគ្គល ប៉ុន្តែ វាមិនអាចជាកត្តា*តែមួយគត់* និងជំនួសកត្តាទាំងអស់ផ្សេងទៀតនោះទេ។ យុត្តាធិការបុគ្គលមិនអាចពឹងផ្អែកតែទៅលើសមាជិកភាពដូចបានចោទប្រកាន់អំពីសហឧក្រិដ្ឋកម្មរួម មិនថាការចូលរួមចំណែកបុគ្គលដូចបានចោទប្រកាន់អាចមានលក្ខណៈយ៉ាងដូចម្ដេចនោះឡើយ[39]។

21. ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ មិនមានមូលដ្ឋានក្នុងការបង្ហាញការអះអាងរបស់ខ្លួនថា មេធាវីការពារក្ដីពុំបានបង្ហាញកំហុសអង្គច្បាប់នៅក្នុងការវិភាគប្រៀបធៀបរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពោលគឺ វិធីដែលគាត់រិតត្បិតដោយប្រយោលលើការវិភាគរបស់គាត់ចំពោះ ឌុច និង អ៊ឹម ចែម នៅពេលមានកម្មាភិបាលខ្មែរក្រហមផ្សេងៗទៀតដែលគេស្គាល់ដូចជា តាម៉ុក, កែ ពក និង សៅ សារុន[40]។ ពាក្យ "ការទទួលខុសត្រូវខ្ពស់បំផុត" បង្កប់អត្ថន័យអំពីភាពចាំបាច់ត្រូវវិភាគប្រៀបធៀបរវាងចារីដែលត្រូវបានចោទប្រកាន់ មិនថាពួកគេត្រូវបានស៊ើបអង្កេត ចោទប្រកាន់ កាត់ទោសដោយ អ.វ.ត.ក បើមិនដូច្នោះទេ ការប្រើប្រាស់ពាក្យ "ខ្ពស់បំផុត" នឹងគ្មានអត្ថន័យអ្វីឡើយ។ តាមន័យរបស់វា "ខ្ពស់បំផុត" គឺជាពាក្យប្រៀបធៀបប៉ុណ្ណោះ។

---

[36] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៥-២៦។

[37] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៦។

[38] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ២៧-២៩។

[39] *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៤៩-៥២។

[40] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣០។

អោ អាន កត់សម្គាល់បន្ថែមទៀតថា គ្មានលក្ខខណ្ឌណាមួយបង្ហាញថា ការវិភាគប្រៀបធៀបគួរកម្រិតត្រឹមកម្មាភិបាលខ្មែរក្រហមដែលគេស្គាល់ថានៅរស់រានមានជីវិត ដែល សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងខុសដោយប្រយោល[41]។

22. អាស្រ័យហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានគាំទ្រការអះអាងរបស់គាត់ថា មេធាវីការពារក្តីពុំបានបង្ហាញអំពីវិធី សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បកស្រាយ "ការទទួលខុសត្រូវខ្ពស់បំផុត" នៅក្នុងលក្ខណៈ ទូលំទូលាយពេក និងមិនត្រឹមត្រូវ។

## III. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៥ នៃបណ្តឹងឧទ្ធរណ៍÷ សហព្រះរាជអាជ្ញាអន្តរជាតិ មិនចាប់អារម្មណ៍ និងយល់ច្រឡំចំពោះយុត្តិសាស្ត្ររបស់អង្គបុរេជំនុំជម្រះ និង មិនបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិតជាបានវាយតម្លៃពីភាពជឿជាក់បានយ៉ាងពេញលេញ និង ត្រឹមត្រូវ

23. សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា មេធាវីការពារក្តីមិនបានបង្ហាញឲ្យឃើញថា តើ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ឬអង្គហេតុ នៅពេលវាយតម្លៃលើភស្តុតាងដោយរបៀបណាទេ។ ជាពិសេស សហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើងថា ការព្យាយាមរបស់មេធាវីការពារក្តី "ក្នុងការបង្ខូចតម្លៃសាក្សីគន្លឹះមួយចំនួន បានពឹងផ្អែកមួយផ្នែកធំលើការវិភាគ និងការចោទប្រកាន់ដែលមិនត្រឹមត្រូវចំពោះភាពមិនសមស្របដែលបានសម្រេចរួចហើយថាគ្មានមូលដ្ឋានទេនោះ"[42]។ ការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ មិនគួរឲ្យជឿជាក់បាន និងមិនត្រឹមត្រូវទេ។ ទីមួយ គាត់និយាយបន្ទរបន្ថយចំពោះការច្រានចោល និងការបដិសេធដោយផ្ទាល់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអនុវត្តតាមសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/១ ពាក់ព័ន្ធនឹងការវាយតម្លៃភស្តុតាង និងការទទូចរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការជ្រើសរើសវិធីសាស្ត្រដែលផ្អែកលើទម្រង់ជាជាងខ្លឹមសារ ដែល អង្គបុរេជំនុំជម្រះ បានសម្រេចថាមានកំហុសអង្គច្បាប់នោះ។ ទីពីរ គាត់បានមើលរំលងទៅលើអង្គហេតុដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានពន្យល់ពីការ

---

[41] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣០។

[42] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣២។

ពឹងផ្អែកជាខ្លាំងរបស់គាត់ទៅលើសក្ខីកម្មរបស់សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល ទោះបីមានអសង្គតិភាពសំខាន់ៗ និង មានការព្រួយបារម្ភផ្សេងៗទៀតលើភាពជឿជាក់បានក៏ដោយ។ ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញខុសចំពោះ *សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពលើកំណត់ហេតុស្ដាប់ចម្លើយនានាដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតបីរូប ("សាលដីកាស្ដីពីភាពលម្អៀង")*[43] របស់ អង្គបុរេជំនុំជម្រះ និងបកស្រាយមិនត្រឹមត្រូវចំពោះសេចក្ដីសម្រេចនេះ ដើម្បីអះអាងថា មេធាវីការពារក្ដីកំពុងព្យាយាមលើកយកបញ្ហានានាមកធ្វើជាចំណុចវិវាទសាជាថ្មី។ ការពិត បញ្ហានៃភាពលម្អៀងនៅក្នុងសេចក្ដីសម្រេចនោះខុសពីបញ្ហានៃការវាយតម្លៃភស្តុតាង និងភាពជឿជាក់បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ដែលបច្ចុប្បន្នស្ថិតនៅចំពោះមុខ អង្គបុរេជំនុំជម្រះ។

### ក. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានច្រាល និង បដិសេធដោយផ្ទាល់មិនអនុវត្តតាមសេចក្ដីសម្រេចរបស់ អង្គបុរេជំនុំជម្រះ ពាក់ព័ន្ធនឹងការវាយតម្លៃភស្តុតាង

24. សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានជ្រើសរើសវិធីសាស្ត្រដែលផ្អែកលើទម្រង់ជាជាងខ្លឹមសារទេ នៅពេលវាយតម្លៃភស្តុតាង និង បានលើកឡើងថា គាត់គ្រាន់តែ "មិនយល់ស្របជាមួយនឹងការផ្ដល់សំអាងហេតុខ្លះៗរបស់ អង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿង ០០៤/១"[44]។ ការពិត សហព្រះរាជអាជ្ញាអន្តរជាតិ និយាយបន្ទរបន្ថយអំពីជំហររបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងមើលរំលងចំណុចគន្លឹះនានានៅក្នុង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)*។ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលដោយផ្ទាល់នូវសំអាងហេតុក្នុងសំណុំរឿង ០០៤/១ របស់ អង្គបុរេជំនុំជម្រះ និងបានបដិសេធមិនប្រកាន់យកវិធីសាស្ត្ររបស់អង្គបុរេជំនុំជម្រះទេ ទោះបីអង្គបុរេជំនុំជម្រះបានសម្រេចថា វិធីសាស្ត្ររបស់

---

[43] សំណុំរឿងលេខ ០០៤/២/០២-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៣៧) *សាលដីកាលើសំណើរបស់ អោ អាន សុំធ្វើមោឃភាពលើកំណត់ហេតុស្ដាប់ចម្លើយនានាដែលធ្វើឡើងដោយអ្នកស៊ើបអង្កេតបីរូប ("សាលដីកាស្ដីពីភាពលម្អៀង")* ឯកសារ **D338/1/5** ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៧។

[44] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៣។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ជាកំហុសអង្គច្បាប់ក៏ដោយ[45]។ ពាក់ព័ន្ធនឹងសំណុំរឿង ០០៤/១ វិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានអនុវត្តឋានានុក្រមដែលខុសឆ្គងដដែលនេះ ដោយដាក់កំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួននៅខ្ពស់ជាងគេ និងបានបដិសេធមិនធ្វើការពិនិត្យទៅលើខ្លឹមសារនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ និងច្រានចោលភ្លាមៗនូវទម្រង់ផ្សេងៗទៀតនៃភស្តុតាងដោះបន្ទុក[46]។

---

[45] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦០-៦១។ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ៣៥។ សំណុំរឿងលេខ ០០៤/០១/០២-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស (អ.ប.ជ ៥០) *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាដំណោះស្រាយ (សំអាងហេតុ) ("សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/១")* ឯកសារ **D308/3/1/20** ចុះថ្ងៃទី២៨ ខែមិថុនា ២០១៨ កថាខណ្ឌ ២៩-៥៩, ៨០ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១១។

[46] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ១២៣, ១២៧, ១៣០ (ស.ច.ស.អ ពន្យល់ពីឋានានុក្រមនៃភស្តុតាងរបស់ខ្លួនស្តីពីទម្រង់ និងប្រភពនៃភស្តុតាង)។ នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* មេធាវីការពារក្តីបង្ហាញឧទាហរណ៍ជាច្រើនលើសលុបដែល ស.ច.ស.អ ជ្រើសរើសវិធីសាស្ត្រដែលផ្អែកលើលើទម្រង់ជាជាងខ្លឹមសារ នៅពេលវាយតម្លៃភស្តុតាង។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៥៨, ៦០ ជើងទំព័រ ១០៣, ១០៩។ *ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ២៤៦ ជើងទំព័រ ៦០០ (ក្នុងការសន្និដ្ឋាន អោ អាន បានចាត់តាំង ប្រាក់ យុត ជាលេខាស្រុកកំពង់សៀម ស.ច.ស.អ មិនបានពិនិត្យមើលខ្លឹមសារនៃភស្តុតាងរបស់ ប្រាក់ យុត ទេ ដោយទទួលយកដោយមិនចោទសួរទៅលើភស្តុតាងពីកំណត់ហេតុស្តាប់ចម្លើយតែមួយ និងគ្មានការបញ្ជាក់បន្ថែម គឺភស្តុតាងរបស់គាត់ និងមិនពិចារណាទៅលើភាពមិនស៊ីចង្វាក់ជាច្រើនទៀតនៅក្នុងភស្តុតាងផ្សេងទៀត ព្រមទាំងវិធីសាស្ត្រស៊ើបអង្កេតមានមន្ទិលរបស់អ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត។ ឧទាហរណ៍ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយចំនួន ២ ប្រាក់ យុត បានលើកឡើងថា អោ អាន ជាអ្នកចាត់តាំងគាត់ តែនៅក្នុងកំណត់ហេតុស្តាប់ចម្លើយទីមួយ គាត់បានផ្តល់ព័ត៌មាននេះតែនៅក្រោយពេលដែលអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ជាអ្នកបញ្ចេញប្រាប់គាត់ប៉ុណ្ណោះ។ ឯកសារ **D117/70** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.២៥-ឆ.២៨។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.២៥។ នៅពេលសម្ភាសដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ប្រាក់ យុត បានអះអាងថា កង់ ចាប បានប្រាប់គាត់អំពីផែនការ ហើយថា គាត់បានទទួលលិខិតបេសកកម្មមួយច្បាប់ពី កង ចាប។ ឯកសារ **D219/234.1.2** (កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាមួយ ប្រាក់ យុត) EN 00963135-33 ទំព័រ ៤៨-៥១។ ចុងក្រោយ ប្រាក់ យុត បានផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២ ថា នីរសាររបស់ កង ចាប បានប្រាប់គាត់ឲ្យទៅកំពង់ចាម។ ឯកសារ **D219/702.1.95** (ប្រតិចារឹករបស់ ប្រាក់ យុត នៅក្នុងសំណុំរឿង ០០២) EN 01253313-14 ទំព័រ ៤០-៤១។ ហេតុនេះ ស.ច.ស.អ មិនចាប់អារម្មណ៍ទៅលើភស្តុតាងផ្ទុយដែលដោះបន្ទុកពីកិច្ចសម្ភាសន៍មជ្ឈមណ្ឌលឯកសារកម្ពុជា និងសក្ខីកម្មរបស់ ប្រាក់ យុត ក្នុងអំឡុងពេលសវនាការក្នុងសំណុំរឿង ០០២ និងទទួលយកភស្តុតាងពីកំណត់ហេតុស្តាប់ចម្លើយរបស់គាត់ទៅវិញ ទោះបី ការពិតគឺថា ភស្តុតាងនេះដិតដាមទៅដោយសំណួរនាំមុខរបស់អ្នកស៊ើបអង្កេតនៅក្នុង ក.ស.ច.ស ក៏ដោយ) កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨ (ក្នុងការសន្និដ្ឋានថា អោ អាន បានបង្គាប់

25. សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញថា “សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិនិត្យលើតម្លៃស្នូលរបស់ភ័ស្តុតាង ដោយគិតគូរអំពីបញ្ហានៃភាពជឿជាក់ និងជំទាស់ទៅនឹងផ្នែកដែលមិនសមហេតុផល”[47] នោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានរកឃើញឧទាហរណ៍មួយចំនួនប៉ុណ្ណោះ បើប្រៀបធៀបទៅនឹងឧទាហរណ៍នានានៅក្នុង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* ដែលបង្ហាញពីការអនុវត្តវិធីសាស្ត្រដែលផ្អែកលើទម្រង់ជាជាងខ្លឹមសាររបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងការដែលគាត់មិនបានពិនិត្យទៅលើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយអង្គភាពរបស់គាត់[48]។ ជាងនេះទៀត ឧទាហរណ៍ជាច្រើនដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានផ្តល់ឲ្យ កាន់តែពង្រឹងអំណះអំណាងរបស់មេធាវីការពារក្តីតែប៉ុណ្ណោះ ព្រោះថាភ័ស្តុតាងទាំងនោះបង្ហាញពីរបៀបដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលភ័ស្តុតាងដោះបន្ទុកជារហូត និង មិនបានពិនិត្យទៅលើបញ្ហាខ្លឹមសារនៃភាពអាចជឿជាក់បាន

ឲ្យចាប់ខ្លួន តាអាំ ជាថ្មីម្តងទៀត ស.ច.ស.អ មិនបានពិនិត្យទៅលើខ្លឹមសារនៃកំណត់ហេតុស្តាប់ចម្លើយរបស់គាត់។ គាត់បានសំអាងទៅលើការលើកឡើងរបស់ សាត ភាព, ជុំ វង្ស, ពេញ វ៉ា, អ៊ឹម ប៊ុន, ពៅ សារ៉ុម និង ពុត កុល។ សាក្សីទាំង ៤ នាក់នេះមិនត្រឹមតែមិនអាចជឿជាក់បានប៉ុណ្ណោះទេ តែសាក្សីទាំងនេះពុំមានការដឹងដោយផ្ទាល់ពីព្រឹត្តិការណ៍នានាដែលនាំឲ្យមានការចាប់ខ្លួន តាអាំ នោះទេ។ ហេតុនេះ ភ័ស្តុតាងរបស់ សាត ភាព បានមកពីពាក្យចចាមអារាមពីនីរសារម្នាក់ដែលមិនស្គាល់ឈ្មោះរបស់ អោ អាន តែប៉ុណ្ណោះ។ ឯកសារ **D219/504** (កំណត់ហេតុស្តាប់ចម្លើយសាក្សី សាត ភាព) ឆ.១៣៥។ ជុំ វង្ស មិនបានដឹងពីអ្នកដែលបានចេញបញ្ជាឲ្យចាប់ខ្លួននេះទេ ហើយត្រឹមតែនិយាយស្មានថាគឺ អោ អាន ជាអ្នកចេញបញ្ជាទៅវិញ ក្រោយពេលអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត បានប្រាប់ព័ត៌មាននេះដល់គាត់។ ឯកសារ **D219/442** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ជុំ វង្ស) ឆ.៤០-ឆ.៤៥។ ពេញ វ៉ា និយាយស្មានថា អោ អាន បានបញ្ជាឲ្យជំនួយ តាអាំ។ ឯកសារ **D219/226** (កំណត់ហេតុស្តាប់ចម្លើយរបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពេញ វ៉ា) ឆ.១១។ បន្ទាប់មក ស.ច.ស.អ ព្យាយាមបន្ថែមភ័ស្តុតាងដែលមិនពេញលេញនេះ ដោយដកស្រង់នូវកំណត់ហេតុស្តាប់ចម្លើយរបស់ អ៊ឹម ប៊ុន, ជុំ វង្ស, ពៅ សារ៉ុម និង ពុត កុល។ ក៏ប៉ុន្តែ ស.ច.ស.អ លើកឡើងខុសការពិតនូវភ័ស្តុតាងរបស់អ្នកទាំងនោះ ដោយសារពួកគេពិភាក្សាពីការចាប់ខ្លួន តាអាំ ដោយគ្មានការយោងទៅដល់ការបញ្ជារបស់ អោ អាន នោះទេ។ ឯកសារ **D117/50** (កំណត់ហេតុស្តាប់ចម្លើយសាក្សី អ៊ឹម ប៊ុន) ឆ.៤២។ ឯកសារ **D219/284** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ពៅ សារ៉ុម) ឆ.៣៣។ ឯកសារ **D117/56** (កំណត់ហេតុស្តាប់ចម្លើយសាក្សីសាក្សី ជុំ វង្ស) ឆ.១៨។ ឯកសារ **D117/26** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ពុត កុល) ឆ.៤)។

[47] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៣ ជើងទំព័រ ៥៦។

[48] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៥៨-៥៩។ *ឧទាហរណ៍ ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ៥៨-៥៩។ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ២៤៦ ជើងទំព័រ ២៤៦ ជើងទំព័រ ៦០០, កថាខណ្ឌ ២៩៦ ជើងទំព័រ ៧៧៨។

ដូចជា អសង្គតិភាពសំខាន់ៗ ឬ ភាពលម្អៀងរបស់សាក្សី ដែលផ្តល់ភ័ស្តុតាងដាក់បន្ទុកស្តីពីយុត្តាធិការបុគ្គល[49]។

26. ចុងក្រោយ ការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិចារណាតិចតួចទៅលើភ័ស្តុតាងពីភាគីនានា និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនពាក់ព័ន្ធទៅនឹងទឡ្ហីករណ៍របស់មេធាវីការពារក្តីទេ[50] ហើយប្រសិនបើវាជាការពិតក៏ដោយ ក៏ចំណុចនេះមិនបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពិនិត្យទៅលើខ្លឹមសារនៅក្នុងកំណត់ហេតុស្តាប់ចម្លើយដែលធ្វើឡើងដោយអង្គភាពរបស់ខ្លួនដែរ។

27. ហេតុនេះ ការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានអនុវត្តឋានានុក្រមតឹងរ៉ឹង នៅពេលវាយតម្លៃភ័ស្តុតាង ជារឿងមិនត្រឹមត្រូវទេ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានច្រានចោលទាំងស្រុងចំពោះវិធីសាស្រ្តរបស់ អង្គបុរេជំនុំជម្រះ ក្នុងការវាយតម្លៃភ័ស្តុតាង និងបានអនុវត្តតាមឋានានុក្រមនៃភ័ស្តុតាងដែលខ្លួនបង្កើតដោយដាក់កំណត់ហេតុស្តាប់ចម្លើយរបស់ខ្លួនឲ្យមានតំលៃខ្ពស់ជាងគេ និងបានបដិសេធមិនពិនិត្យទៅលើខ្លឹមសាររបស់វា។

### ខ. សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានវាយតម្លៃឲ្យបានត្រឹមត្រូវលើភាពជឿជាក់បានរបស់សាក្សីគន្លឹះ និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ហើយទោះបីមានអសង្គតិភាពសំខាន់ៗ និងមានការព្រួយបារម្ភលើបញ្ហានៃភាពជឿជាក់ផ្សេងៗទៀតក៏ដោយ ក៏គាត់នៅតែពឹងផ្អែកជាចម្បងទៅលើសក្ខីកម្មរបស់បុគ្គលទាំងនោះដែរ ដោយគ្មានការពន្យល់អ្វីទាំងអស់

28. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីភាពជឿជាក់បានរបស់សាក្សីគន្លឹះ និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយថា អង្គបុរេជំនុំជម្រះ គួរ "មិនចង់រំខានដល់ការវាយតម្លៃនេះទេ *លែងតែ*មានការ

---

[49] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៣ ជើងទំព័រ ៥៦។

[50] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៣។

រំលោភបំពានឆន្ទានុសិទ្ធិ"[51]។ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងបែបនេះមិនត្រឹមត្រូវទេ។ ទីមួយ គាត់លើកឡើងមិនត្រឹមត្រូវពីបទដ្ឋាននៃការពិនិត្យឡើងវិញ ដើម្បីចេញសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិ។ អង្គបុរេជំនុំជម្រះ បានសម្រេចនៅក្នុងសំណុំរឿង ០០៤/១ ថា អង្គបុរេជំនុំជម្រះអាចបដិសេធចោលសេចក្តីសម្រេចតាមឆន្ទានុសិទ្ធិពាក់ព័ន្ធនឹងយុត្តាធិការបុគ្គល នៅពេលមានកំហុសអង្គច្បាប់ កំហុសអង្គហេតុ *ឬ* ការបំពារបំពានឆន្ទានុសិទ្ធិ ដែលធ្វើឱ្យប៉ះពាល់ជាមូលដ្ឋានទៅលើការអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួន[52]។

29. ទីពីរ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ ផ្តោតតែទៅលើសង្គតិភាពនៃការលើកឡើងរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីក្នុងការសម្រេចពីភាពជឿជាក់[53] ប៉ុណ្ណោះ។ ក្នុងការធ្វើបែបនេះ គាត់យល់ខុសពីទស្សនៈស្តីពីភាពជឿជាក់។ ភាពជឿជាក់មិនមែនផ្តោតតែទៅលើសង្គតិភាព ឬ អសង្គតិភាពនៅក្នុងចម្លើយរបស់បុគ្គលទាំងនោះប៉ុណ្ណោះទេ ទោះបីវាជាកត្តាមួយសំខាន់ក៏ដោយ តែក៏ត្រូវរួមបញ្ចូលទាំងការវាយតម្លៃអំពីការជំរុញការនិយាយកុហក ការបញ្ជាក់បន្ថែម និងវិធីតាំងសំណួរដល់បុគ្គលទាំងនោះផងដែរ[54]។ ក្នុងសភាពជាក់ស្តែង ដូចបានលើកឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានធ្វើវាយតម្លៃតិចតួច ឬមិនបានវាយតម្លៃ ពីភាពជឿជាក់បាន ដោយមិនចាប់អារម្មណ៍ទៅលើអសង្គតិភាពសំខាន់ៗ និង មើលរំលងហេតុផលនាំឱ្យមានការនិយាយកុហក ពុំមានការបញ្ជាក់បន្ថែម ហើយវិធីសាស្រ្តគួរឱ្យមន្ទិលរបស់អ្នកស៊ើបអង្កេតនៅ ក.ស.ច.ស[55]។

30. ទីបី សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនតម្រូវឱ្យពន្យល់អំពីអសង្គតិភាពសំខាន់ៗនៅក្នុងការលើកឡើងរបស់សាក្សី និង អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីទេ ដោយសារពុំមានអសង្គតិភាពទាល់តែសោះ[56]។ ហេតុនេះ សហព្រះរាជ

---

[51] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៤ (គូសបញ្ជាក់បន្ថែម)។

[52] *សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/១* កថាខណ្ឌ ២១។ *សូមមើលផងដែរ* កថាខណ្ឌ ៤៣, ១៤២, ១៦០, ៣២០-៣៤០។

[53] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៤។

[54] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦២-៧៧។

[55] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦២-៧៧។

[56] *ឧទា. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៦ ជើងទំព័រ ៦៧។

អាជ្ញាអន្តរជាតិ ទទួលស្គាល់ថា ត្រូវតែមានការពន្យល់ចំពោះអសង្គតិភាពសំខាន់ៗដែរ។ សហព្រះរាជអាជ្ញាអន្តរជាតិ បានដកស្រង់ដោយ ត្រឹមត្រូវនូវយុត្តិសាស្ត្រ (ដែលថា អ្នកវិនិច្ឆ័យអង្គហេតុត្រូវពន្យល់ពីមូលហេតុដែលពួកគេពឹងផ្អែកជាចម្បងពីក្រោយការប្រើ សក្ខីកម្ម ទោះបីមានអសង្គតិភាពសំខាន់ៗក៏ដោយ)[57] ប៉ុន្តែបានអះអាងដោយមិនត្រឹមត្រូវថា ពុំមានអសង្គតិភាពសំខាន់ៗទេ។ មេធាវីការពារក្តីបានលើកឡើងពីអសង្គតិភាពសំខាន់ៗជាច្រើននៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន*[58] ជាពិសេស ទាក់ទិននឹងសាក្សី ប្រាក់ យុត និងការព្យាយាមរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ក្នុងការបដិសេធអសង្គតិភាពទាំងនេះ មិនអាចទទួលយកបានទេ[59]។ ហេតុនេះ នៅក្នុង *ដីកា*

[57] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៤។

[58] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦២-៧៥, ៨៦, ៨៩, ៩៥, ១០៨, ១១១, ១២១, ១២៥, ១២៧, ១៤២-១៤៣។

[59] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៥-៣៨ ជើងទំព័រ ៦៧ (ស.ព.អ បង្ហាញខុស និង រើសយកភ័ស្តុតាងតាមការចង់បានដើម្បីគាំទ្រដល់ការអះអាងរបស់គាត់ដែលថា ប្រាក់ យុត បានកំណត់អត្តសញ្ញាណយ៉ាងស្របគ្នាថា អោ អាន ជាអ្នកដែលចាត់តាំងគាត់ធ្វើជាលេខាស្រុក។ ការវិភាគទៅលើភ័ស្តុតាងយ៉ាងល្អិតល្អន់ និងយ៉ាងយកចិត្តទុកដាក់ រួមទាំងការមិនលើកឡើងរបស់ ប្រាក់ យុត បង្ហាញថា ប្រាក់ យុត ពុំមានសង្គតិភាពទេទៅលើបញ្ហានេះ។ ឯកសារ **D360/5/1.5** (ឧបសម្ព័ន្ធ ឃ៖ អសង្គតិភាពរបស់ ប្រាក់ យុត ទាក់ទងទៅនឹងយុត្តាធិការបុគ្គល) EN 01599796-98 ទំព័រ ៣-៥។ ឯកសារ **D6.1.721** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.២-ឆ.៣ (ប្រាក់ យុត លើកឡើងថា កង ចាប ជាអ្នកបញ្ជាឱ្យគាត់ផ្លាស់ទៅភូមិភាគកណ្តាល)។ ឯកសារ **D179/1.2.4** (ប្រតិចារឹករបស់ ប្រាក់ យុត នៅក្នុងសំណុំរឿង ០០២) EN 00773507, 00773509-10 ទំព័រ ៧២, ៧៤-៧៥ (ប្រាក់ យុត បានផ្តល់សក្ខីកម្មថា កង ចាប ជាអ្នកហៅគាត់ទៅរៀនសូត្រ និងបញ្ជូនទៅកំពង់ចាម ជាពិសេសនៅស្រុកកំពង់សៀម។ បន្ទាប់មក គាត់បានលើកឡើងថា តួនាទីរបស់គាត់នៅស្រុកកំពង់សៀមគឺជាលេខាស្រុក ហើយថា គាត់ធ្វើតាមបញ្ជារបស់ កង ចាប ដែលទៅទីនោះ។ គាត់មិនបានលើកឡើងអំពី អោ អាន ទេ)។ ឯកសារ **D117/70** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.៦-ឆ.១០, ឆ.១៨-ឆ.២១, ឆ.២៦ (ចុងក្រោយ ប្រាក់ យុត ពិភាក្សាអំពីតួនាទីរបស់ កង ចាប, កែ ពក និង អោ អាន ពាក់ព័ន្ធនឹងការចាត់តាំងរូបគាត់ជាលេខាស្រុក តែ អ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត មិនបានសួរសំណួរបន្ត ដើម្បីបញ្ជាក់បំភ្លឺថាតើនរណាជាអ្នកចាត់តាំងគាត់ពិតប្រាកដនោះទេ)។ ឯកសារ **D117/71** (កំណត់ហេតុស្តាប់ចម្លើយសាក្សី ប្រាក់ យុត) ឆ.១៩ (ប្រាក់ យុត បានលើកឡើងថា កែ ពក បានចាត់តាំងគាត់ និងអ្នកផ្សេងទៀតឱ្យទៅកាន់តំណែងរបស់ខ្លួន)។ ឯកសារ **D219/234.1.2** (កិច្ចសម្ភាសន៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជា ជាមួយ ប្រាក់ យុត) EN 00963126, 00963135-33 ទំព័រ ៣៩, ៤៨-៥១ (ប្រាក់ យុត លើកឡើងថា តាចាប និងប្រាប់គាត់ និង អ្នកផ្សេងទៀតឱ្យផ្លាស់ទៅកំពង់ចាម ពួកគេបានធ្វើដំណើរការទៅកំពង់ចាម ដែលនៅទីនោះ គាត់បានរង់ចាំទទួលភារកិច្ចរបស់ខ្លួននៅឯការប្រជុំកម្រិតគណៈកម្មាធិការភូមិភាគ តាចាប ជាអ្នកប្រាប់គាត់ពីការប្រជុំនេះ ហើយ តាចាប ក៏បានបញ្ជូនលិខិតបេសកកម្មមួយច្បាប់ ហើយពួកគាត់ត្រូវធ្វើតាមការណែនាំ)។ ឯកសារ **D219/702.1.95** (ប្រតិចារឹករបស់ ប្រាក់ យុត នៅក្នុងសំណុំរឿង ០០២) **D219/702.1.95** (ប្រតិចារឹករបស់ ប្រាក់ យុត នៅក្នុងសំណុំរឿង ០០២) EN 01253313-15 ទំព័រ ៤០-៤២ 56-58 (ប្រាក់ យុត បានផ្តល់សក្ខីកម្មថា កង ចាប បានបញ្ជូននីរសារម្នាក់ទៅប្រាប់គាត់ថា គាត់នឹងផ្លាស់ទៅកំពង់ចាម ហើយ

*ដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ គួរតែពន្យល់ឱ្យបានពេញលេញពីមូលហេតុដែលគាត់ពឹងផ្អែកជាចម្បងទៅលើសាក្សីមួយចំនួន (ដូចជា ប្រាក់ យុត)ទោះបីមានអសង្គតិភាពសំខាន់ៗ និងមានការព្រួយបារម្ភពីភាពជឿជាក់បាននៃសាក្សីនេះក៏ដោយ តែគាត់មិនបានពន្យល់បែបនេះទេ[60]។

## គ. មេធាវីការពារក្ដីមិនលើកយកបញ្ហាទាំងនេះមកធ្វើជាចំណុចវិវាទសាជាថ្មីទេ តែផ្ទុយទៅវិញ សហព្រះរាជអាជ្ញាអន្តរជាតិ យល់ច្រឡំចំពោះសាលដីកាស្ដីពី

---

បន្ទាប់មក គាត់បានបញ្ជាក់ថា គាត់បានជួប កង ចាប តែម្នាក់គត់ពាក់ព័ន្ធនឹងការចាត់តាំងគាត់ទៅកំពង់ចាម), កថាខណ្ឌ ៣៩ ជើងទំព័រ ៧៧ (ស.ព.អ បង្ហាញភ័ស្តុតាងមិនត្រឹមត្រូវក្នុងការព្យាយាមបង្ហាញថា យូ វ៉ាន់ បានផ្តល់ចម្លើយស្របគ្នា។ ពាក់ព័ន្ធនឹងការអះអាងពីបញ្ហារបស់ អោ អាន អំពីការរៀបអាពាហ៍ពិពាហ៍ ដំបូងសហព្រះរាជអាជ្ញាអន្តរជាតិ បានសំអាងទៅលើ ឯកសារ **D219/138** (កំណត់ហេតុស្ដាប់ចម្លើយសាក្សី យូ វ៉ាន់) ឆ.៨០ ដែល យូ វ៉ាន់ បានផ្តល់ភ័ស្តុតាងបែបចចាមអារាមអំពីការបញ្ជារបស់ អោ អាន ឱ្យប្ដីប្រពន្ធដែលទើបនឹងរៀបចំត្រូវរួមដំណេកជាមួយគ្នា។ បន្ទាប់មក សហព្រះរាជអាជ្ញាអន្តរជាតិ បានសន្និដ្ឋានចេញពីពាក្យចចាមអារាមនេះថា ចម្លើយនេះស្របទៅនឹងចម្លើយនៅក្នុងឯកសារ **D219/701.1.87** (ប្រតិចារឹករបស់ យូ វ៉ាន់)។ ក៏ប៉ុន្តែ នៅក្នុងឯកសារ **D219/701.1.87** (ប្រតិចារឹករបស់ យូ វ៉ាន់) EN 01431623-24 ទំព័រ ៣៧-៣៨ (ភាសាអង់គ្លេស) យូ វ៉ាន់ បានពិភាក្សាអំពីការហាមឃាត់មិនឱ្យរៀបការរវាងជាតិពន្ធុមួយទៅជាតិពន្ធុមួយទៀត ហើយគ្រាន់តែលើកឡើងថា បញ្ជានោះមកពី "ថ្នាក់លើ" ដោយមិនបាននិយាយដល់ អោ អាន ទេ)។

[60] *ឧទា. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៦ ជើងទំព័រ ៦៨។ **ថាតើក្រុមភូមិភាគនិរតីបានទៅដល់ភូមិភាគកណ្ដាលនៅដើមឆ្នាំ១៩៩៧ មែន ឬអត់៖** សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា ស.ច.ស.អ បានពិចារណាយ៉ាងត្រឹមត្រូវដល់ភ័ស្តុតាងដែលអសង្គតិភាពរបស់ ប្រាក់ យុត ស្ដីពីពេលវេលានៃការទៅដល់ភូមិភាគកណ្ដាល។ សហព្រះរាជអាជ្ញាអន្តរជាតិផ្ដល់យោបល់ថា ស.ច.ស.អ បានពិចារណាដល់ភ័ស្តុតាងដោះបន្ទុកពីបុគ្គលផ្សេងទៀត ដោយសារគាត់ប្រើពាក្យថា "*ប្រៀបធៀបទៅនឹង*" នៅក្នុងជើងទំព័រ។ ការយោងនេះមិនបានបង្កើតជាការពន្យល់ចំពោះការមិនពិចារណាដល់ភ័ស្តុតាងដោះបន្ទុកនេះទេ។ **ថាតើ អោ អាន បានធ្វើដំណើរទៅកាន់ភូមិភាគកណ្ដាលជាមួយនឹង ប្រាក់ យុត មែន ឬអត់៖** សហព្រះរាជអាជ្ញាអន្តរជាតិ បានផ្តល់សំអាងហេតុមិនត្រឹមត្រូវតាមវិធីសាស្ត្រដូចខាងលើចំពោះចម្លើយដែលអសង្គតិភាពអំពីការណ៍ដែល អោ អាន បានធ្វើដំណើរទៅភូមិភាគកណ្ដាលជាមួយគាត់។ **ថាតើ អោ អាន បានធ្វើការ "បោសសម្អាត" អតីតកម្មាភិបាលភូមិភាគកណ្ដាល មែន ឬអត់៖** សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់ថា ស.ច.ស.អ មិនបានសំអាងទៅលើចម្លើយដែលអសង្គតិភាពរបស់ ប្រាក់ យុត ពាក់ព័ន្ធនឹងការបោសសម្អាតអតីតកម្មាភិបាលនៅស្រុកកំពង់សៀមទេ។ ចំណុចនេះមិនត្រឹមត្រូវទេ។ នៅក្នុងកថាខណ្ឌ ២៩៧ នៃ *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* ស.ច.ស.អ បានសន្និដ្ឋានថា អោ អាន បានបញ្ជាឱ្យបោសសម្អាតកម្មាភិបាលនៅថ្នាក់ស្រុក ហើយបន្ទាប់មកបានសន្និដ្ឋានថា បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយ កែ ពក អោ អាន បានបញ្ជាឱ្យចាប់ខ្លួនមេឃុំចាស់ៗ និងយកកម្មាភិបាលពីភូមិភាគនិរតីទៅជំនួសពួកគេ។ ក្នុងការសន្និដ្ឋានបែបនេះ ស.ច.ស.អ បានពឹងផ្អែកជាខ្លាំងទៅលើ ប្រាក់ យុត នៅក្នុងជើងទំព័រ ៧៨៣ និង ៧៨៤។

**ភាពលម្អៀងរបស់**
**អង្គបុរេជំនុំជម្រះ**

31. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា ការអះអាងជាច្រើនរបស់មេធាវីការពារក្តីដែលថាសាក្សីប្រាក់ យុត ត្រូវបានផ្តល់ព័ត៌មានដាក់បន្ទុក ត្រូវបាន "ច្រានចោលជាឯកច្ឆ័ន្ទដោយ អង្គបុរេជំនុំជម្រះ រួចហើយ"[61] ហើយបានធ្វើការអះអាងស្រដៀងគ្នានេះដែរពាក់ព័ន្ធនឹងភ័ស្តុតាងរបស់សាក្សី យូ វ៉ាន់ និង ញ៉ែម ចេន[62]។ ក្នុងការអះអាងទាំងនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញខុសពីខ្លឹមសារនៃ *សាលដីកាស្តីពីភាពលម្អៀង* របស់ អង្គបុរេជំនុំជម្រះ ដែលផ្តោតទៅលើថា តើអ្នកស៊ើបអង្កេតនៅក្នុង ក.ស.ច.ស មានភាពលម្អៀង ឬយ៉ាងណា។

32. នៅក្នុង *សាលដីកាស្តីពីភាពលម្អៀង* អង្គបុរេជំនុំជម្រះ បានសម្រេចថា ភាពលម្អៀងរបស់អ្នកស៊ើបអង្កេតនៅ ក.ស.ច.ស មិនអាចបញ្ជាក់បានទេ[63] តែអង្គជំនុំជម្រះក៏បានលើកឡើងផងដែរថា ករណីនៃ "ការផ្តល់" ព័ត៌មានដាក់បន្ទុក ឬ ការចោទប្រកាន់ពីអសង្គតិភាព "ពាក់ព័ន្ធនឹងការវាយតម្លៃលើភាពជឿជាក់បាន និងភាពទុកចិត្តបាននៃភ័ស្តុតាង ដែលនឹងត្រូវធ្វើឡើងនៅដំណាក់កាលក្រោយប៉ុណ្ណោះ [ដំណាក់កាលចេញដីកាដំណោះស្រាយ]"[64]។ អង្គបុរេជំនុំជម្រះ បានសម្រេចជាពិសេសថា "កាលៈទេសៈនៃការប្រមូលភ័ស្តុតាង រួមទាំង ភាពអាចទុកចិត្តបាននៃកិច្ចស្តាប់ចម្លើយពាក់ព័ន្ធនឹងលក្ខណៈនៃសំណួរដែលបានសួរទៅកាន់សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវយកមកវាយតម្លៃពេញលេញនៅដំណាក់កាលចេញដីកាដំណោះស្រាយដោយ [អង្គបុរេជំនុំជម្រះ]"[65]។ នាពេលនេះ យើងស្ថិតនៅក្នុងដំណាក់កាលនោះហើយ។ ហេតុនេះ មេធាវីការពារក្តីពុំបានលើកពីបញ្ហាលម្អៀងមកធ្វើជាចំណុចវិវាទសាជាថ្មីទេ ដោយសារបញ្ហានេះត្រូវបានសម្រេចរួចហើយ តែផ្ទុយទៅវិញ មេធាវីការពារក្តីកំពុងលើកឡើងយ៉ាងត្រឹមត្រូវ និងទាន់ពេលវេលាពីបញ្ហានៃភាពជឿ

---

[61] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៧ ជើងទំព័រ ៧០។

[62] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៣៩ ជើងទំព័រ ៧៦, កថាខណ្ឌ ៤២ ជើងទំព័រ ៨៩។

[63] *សាលដីកាស្តីពីភាពលម្អៀង* កថាខណ្ឌ ២១។

[64] *សាលដីកាស្តីពីភាពលម្អៀង* កថាខណ្ឌ ២៣-២៤។

[65] *សាលដីកាស្តីពីភាពលម្អៀង* កថាខណ្ឌ ២៥។

ជាក់បាន និងភាពទុកចិត្តបាននៃភ័ស្តុតាង[66]។

33. ហេតុនេះ នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* មេធាវីការពារក្តីបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ និងអង្គហេតុ នៅពេលវាយតម្លៃទៅលើភ័ស្តុតាង។ សហព្រះរាជអាជ្ញាអន្តរជាតិ និយាយបន្ទរបន្ទាយការច្រានចោល និងការបដិសេធជាក់ស្តែងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអនុវត្តតាមសេចក្តីសម្រេចរបស់ អង្គបុរេជំនុំជម្រះ នៅក្នុងសំណុំរឿង ០០៤/១ ពាក់ព័ន្ធនឹងការវាយតម្លៃភ័ស្តុតាង។ គាត់បានអះអាងដោយខុសឆ្គងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីភាពជឿជាក់បានរបស់សាក្សី និងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយគាត់បានបង្ហាញមិនត្រឹមត្រូវពី *សាលដីកាស្តីពីភាពលម្អៀង* របស់ អង្គបុរេជំនុំជម្រះ។

## IV. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៦ នៃបណ្តឹងឧទ្ធរណ៍៖ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងយុត្តាធិការបុគ្គល ជារឿងមិនត្រឹមត្រូវ និងគ្មានភ័ស្តុតាងគាំទ្រ

34. ពាក់ព័ន្ធនឹងមូលដ្ឋានទី ៦ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបដិសេធគួរឲ្យជឿជាក់បានទៅលើទឡ្ហីករណ៍របស់មេធាវីការពារក្តីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសអង្គច្បាប់ ក្នុងការកំណត់ថា អ.វ.ត.ក មានយុត្តាធិការបុគ្គលទៅលើ អោ អាន នោះទេ។ សហព្រះរាជអាជ្ញាអន្តរជាតិ ក៏មិនបានបដិសេធពីកំហុសអង្គហេតុដែលមេធាវីការពារក្តីសន្និដ្ឋាននៅក្នុង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* ពាក់ព័ន្ធនឹងការចោទប្រកាន់ពីតំណែង តួនាទី និង ការចូលរួមរបស់ អោ អាន នៅក្នុងបទឧក្រិដ្ឋនានាដែលត្រូវបានចោទប្រកាន់នៅក្នុងតំបន់ ៤១ ឬ ភូមិភាគកណ្តាលដែរ។ ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិ បានបកស្រាយខុសចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តី ទាក់ទិននឹងភ័ស្តុតាងចចាមអារ៉ាម។ ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិ យល់ខុសអំពីទស្សនៈរបស់ភ័ស្តុតាងបញ្ជាក់បន្ថែម នៅក្នុងការវិភាគទាំងមូលរបស់គាត់ទៅលើកំហុសអង្គហេតុជាក់លាក់ ដែលមេធាវីការពារក្តីបានរកឃើញ។ ចុងក្រោយ

[66] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦២-៧៥។

សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញមិនត្រឹមត្រូវពីភស្តុតាងនៃការព្យាយាមធ្វើយុត្តិកម្ម ចំពោះកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

## ក. សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសចំពោះទឡ្ហីករណ៍របស់ អោ អាន ទាក់ទិននឹងភស្តុតាងចចាមអារ៉ាម

35. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា អោ អាន "ជំទាស់ជារហូតទៅលើការសន្និដ្ឋានផ្នែកអង្គហេតុ ដោយសំអាងលើមូលដ្ឋានថា ការសន្និដ្ឋានទាំងនោះផ្អែកលើភស្តុតាងចចាមអារ៉ាម"[67]។ ក្នុងការអះអាងបែបនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បកស្រាយខុសចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីទាក់ទិននឹងភស្តុតាងចចាមអារ៉ាម។ មេធាវីការពារក្តីមិនបានជំទាស់ថា ភស្តុតាងចចាមអារ៉ាមទាំងអស់មិនអាចទទួលយកបាននោះទេ តែផ្ទុយទៅវិញ មេធាវីការពារក្តីបញ្ជាក់ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ត្រូវមានការប្រុងប្រយ័ត្ននៅពេលសំអាងទៅលើពាក្យចចាមអារ៉ាម តែគាត់មិនប្រុងប្រយ័ត្នបែបនេះឡើយ[68]។ នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* មេធាវីការពារក្តីបានផ្តល់ឧទាហរណ៍ជាក់លាក់ពីចំណុចដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនប្រុងប្រយ័ត្នបែបនេះ ហើយប្រសិនបើគាត់មានការប្រុងប្រយ័ត្នមែន គាត់ប្រាកដជាមិនសម្រេចថា អោ អាន ស្ថិតក្នុងយុត្តាធិការបុគ្គលរបស់តុលាការនេះទេ[69]។

36. លើសពីនេះទៀត ដូចដែល សហព្រះរាជអាជ្ញាអន្តរជាតិ បានធ្វើរួចមកហើយ ការសន្មតថា ភស្តុតាងចចាមអារ៉ាមមានតម្លៃជាភស្តុតាងស្មើនឹងភស្តុតាងផ្ទាល់ ដោយផ្អែកលើការដឹងឮផ្ទាល់ ជាការផ្ទុយទៅនឹងយុត្តិសាស្ត្រដែលមេធាវីការពារក្តី និង សហព្រះរាជអាជ្ញាអន្តរជាតិ បានដកស្រង់[70]។

37. ចុងក្រោយ វាមិនមែនជាការពិតទេនៅពេលដែលសហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថាព័ត៌មានចចាមអារ៉ាមទទួលបានពី ប្រាក់ យុត បង្ហាញពីសង្គតិភាពរបស់គាត់ "ជាច្រើនទសវត្សរ៍មក

---

[67] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥២។

[68] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៨។

[69] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៨។

[70] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥២ ជើងទំព័រ ១២៥។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៨ ជើងទំព័រ ១៧៤។

ហើយ"[71] ។ សហព្រះរាជអាជ្ញាអន្តរជាតិ និយាយស្មានៗ "តាមរយៈបរិបទ និងពាក្យពេចន៍" ថា ភ័ស្តុតាងចចាមអារ៉ាមនេះ "ស្ទើរតែ" ត្រូវបាននិយាយតាំងពី ៣០ឆ្នាំ មុន[72]។ ការនិយាយស្មានៗ របស់គាត់គឺព្យាយាមតតាំងចំពោះការព្រួយបារម្ភចម្បងរបស់មេធាវីការពារក្ដីអំពីសាក្សី ប្រាក់យុត ដែលអាចមានការទាក់ទង និងការជ្រៀតជ្រែកដល់សក្ខីកម្មរបស់សាក្សី ក្នុងអំឡុងពេលស៊ើបអង្កេតរបស់ ក.ស.ច.ស[73]។ មេធាវីការពារក្ដីនៅតែរក្សាជំហររបស់ខ្លួនដដែល និង អះអាងសាជាថ្មីពីការព្រួយបារម្ភរបស់ខ្លួនពាក់ព័ន្ធនឹងភ័ស្តុតាងនេះ ដូចបានលើកឡើងក្នុង *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន*[74]។

**ខ. សហព្រះរាជអាជ្ញាអន្តរជាតិ យល់ខុសចំពោះទស្សនៈនៃភ័ស្តុតាងបញ្ជាក់បន្ថែម** (corroborative evidence)

38. ក្នុងការឆ្លើយតបទៅនឹងកំហុសអង្គហេតុនានាដែលមេធាវីការពារក្ដីបានលើកឡើងពាក់ព័ន្ធនឹងការចោទប្រកាន់ទៅលើតួនាទី និងមុខងាររបស់ អោ អាន នៅក្នុងតំបន់ ៤១ សហព្រះរាជអាជ្ញាអន្តរជាតិ បានចោទប្រកាន់ជាចម្បងថា មេធាវីការពារក្ដីបានប្រកាន់យកវិធីសាស្ត្រ "មួយផ្នែកម្ដងៗ" ចំពោះការវាយតម្លៃភ័ស្តុតាង ជំនួសឱ្យវិធីសាស្ត្រ "ត្រួតគ្នា"[75]។ ក្នុងការចោទប្រកាន់បែបនេះ សហព្រះរាជអាជ្ញាអន្តរជាតិ បានបង្ហាញពីការយល់ច្រឡំជាមូលដ្ឋានចំពោះទស្សនៈនៃភ័ស្តុតាងបញ្ជាក់បន្ថែម[76]។ ការយល់ច្រឡំនេះបណ្ដាលឱ្យ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានធ្វើការពិនិ

---

[71] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៣។

[72] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៣។

[73] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៣។

[74] *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៨-៧៩។

[75] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៥-៥៧។

[76] *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Ruto, Kosgey និង Sang* សំណុំរឿងលេខ ICC-01/09-01/11 *សេចក្ដីសម្រេចលើការបញ្ជាក់អំពីបទចោទ អនុលោមតាមមាត្រា ៦១(៧)(ក) និង (ខ) នៃលក្ខន្តិកៈទីក្រុងរ៉ូម* ចុះថ្ងៃទី២៣ ខែមករា ឆ្នាំ២០១២ កថាខណ្ឌ ២៩៣-២៩៤ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១២ (ដោយបដិសេធមិនបញ្ជាក់បទចោទប្រឆាំងនឹងចុងចោទ ដោយផ្អែកលើការលើកឡើងដែលគ្មានការបញ្ជាក់បន្ថែមរបស់សាក្សីអនាមិក អំពីតួនាទីរបស់ចុងចោទនៅក្នុងអង្គការ)។ *រឿងក្ដី រដ្ឋអាជ្ញា តទល់នឹង Lubanga Dyilo* Case សំណុំរឿងលេខ ICC-01/04-01/06 *សេចក្ដីសម្រេចលើការបញ្ជាក់អំពីបទចោទ* (*"សេចក្ដីសម្រេចលើការបញ្ជាក់អំពីបទចោទលើរឿងក្ដី Lubanga"*) ចុះថ្ងៃទី២៩ ខែមករា ឆ្នាំ២០០៧ កថាខណ្ឌ ១២១-១២២ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៣ (ដោយអនុវត្តតាម

ត្យថា តើភស្តុតាងបញ្ជាក់បន្ថែមគាំទ្រដល់ការធ្វើសេចក្តីសន្និដ្ឋាននីមួយៗរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលបណ្តាលឲ្យប៉ះពាល់ដល់ការសម្រេចទៅលើយុត្តាធិការបុគ្គល ឬយ៉ាងណាទេ[77]។

39. ទោះបី អង្គជំនុំជម្រះតុលាការកំពូល បានសម្រេចថា ពុំមាន "វិធានទូទៅ" ដែលតម្រូវឲ្យមានការបញ្ជាក់បន្ថែមក៏ដោយ ក៏ភស្តុតាងបញ្ជាក់បន្ថែមពិតជាមានសារៈសំខាន់ដែរ។ ទីមួយ បទដ្ឋាននៃការបង្ហាញភស្តុតាងកំណត់ថា ការបញ្ជាក់បន្ថែមគឺជាចំណុចសំខាន់នៃការវិភាគភស្តុតាង ("ភស្តុតាងពិតប្រាកដ និងភស្តុតាងមានការបញ្ជាក់គ្រប់គ្រាន់")។ ទីពីរ បទដ្ឋានរបស់ អ.វ.ត.ក ស្របទៅនឹងការអនុវត្ត និងយុត្តិសាស្ត្រនៅតាមសាលាក្តីអន្តរជាតិ និងនៅក្នុងយុត្តាធិការតុលាការជាតិនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល (Civil Law)[78]។ តុលាការនានាបានទទួលស្គាល់ថា ការបញ្ជាក់បន្ថែមហាក់ដូចជាជាលក្ខខណ្ឌកំណត់ នៅពេលសាក្សី ឬអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ពុំមានភាពអាចជឿជាក់បាន ទាំងទៅលើអង្គហេតុសំខាន់ជាក់លាក់ណាមួយ ឬអង្គហេតុទាំងមូល។ ហេតុនេះ ភស្តុតាងបញ្ជាក់បន្ថែមគួរត្រូវបានតម្រូវ ដើម្បីគាំទ្រដល់ភស្តុតាងរបស់ ប្រាក់ យុត និងអ្នកផ្សេងទៀតដែលបានបង្ហាញនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន*[79]។

40. នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ បានរិះគន់ដល់វិធីសាស្ត្ររបស់មេធាវីការពារក្តីក្នុងការវាយតម្លៃភស្តុតាងថា "មួយផ្នែកម្តងៗ" ដោយសារមេធាវីការពារក្តីបានពិនិត្យថា តើការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុ*នីមួយៗ* ត្រូវបានគាំទ្រដោយភស្តុតាងពិតប្រាកដ និងភស្តុ

---

យុត្តាធិការពីតុលាការ ICTR អង្គបុរេជំនុំជម្រះ I បានសម្រេចថា ជាទូទៅ ផ្នែកនៃសក្ខីកម្មដែលមានការបញ្ជាក់បន្ថែម មានតម្លៃភស្តុតាងខ្ពស់ជាង ផ្នែកផ្សេងទៀត)។

[77] *ឧទា. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤៨, ៥២-៥៣, ៦០-៦៣, ៦៧-៦៨, ៧៣-៧៧, ៨១។

[78] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៧។

[79] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៦៣-៧៥។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Ruto និង Sang* សំណុំរឿងលេខ ICC-01/09-01/11 *សេចក្តីសម្រេចទៅលើពាក្យសុំរបស់មេធាវីការពារក្តី ដែលស្នើសុំឲ្យចេញសាលក្រមលើកលែងការចោទប្រកាន់ សំអាងហេតុរបស់ចៅក្រម Fremr* ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១៦ កថាខណ្ឌ ៥៦-៥៧ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៤ (ដោយធ្វើការសន្និដ្ឋានថា នៅពេលមានសាក្សីតែម្នាក់ដែលគ្មានការបញ្ជាក់ គាំទ្រដល់ការចោទប្រកាន់ជាក់លាក់ណាមួយ ភស្តុតាងនេះមិន "ក្លាយជាមូលដ្ឋានរឹងមាំចាំបាច់ដែល [អង្គជំនុំជម្រះ] សមហេតុផល អាចយកមកសំអាងដើម្បីធ្វើការផ្តន្ទាទោសឲ្យបានសមរម្យបានទេ")។ *សេចក្តីសម្រេចលើការបញ្ជាក់អំពីបទចោទលើរឿងក្តី Lubanga* កថាខណ្ឌ ១២១-១២២។

តាងមានការបញ្ជាក់គ្រប់គ្រាន់ ឬទេ នោះគឺថា តើភ័ស្តុតាងទាំងនោះស្របទៅនឹងបទដ្ឋាននៃការបង្ហាញភ័ស្តុតាង ឬយ៉ាងណា[80]។ សហព្រះរាជអាជ្ញាអន្តរជាតិ ពេញចិត្តនឹងអ្វីដែលគាត់ហៅថា វិធីសាស្ត្រ "ត្រួតគ្នា" ជាង នៅពេលគាត់ភ្ជាប់ដោយមិនត្រឹមត្រូវនូវការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុជាច្រើនបញ្ចូលគ្នា ដើម្បីធ្វើជា "ភ័ស្តុតាងបញ្ជាក់បន្ថែម"[81]។ វិធីសាស្ត្រនេះមិនស្របទៅនឹងយុត្តិសាស្ត្រអន្តរជាតិទេ[82]។ ការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុនីមួយៗដែលជាមូលដ្ឋាននៃការសម្រេច

---

[80] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៥៥-៥៧។

[81] *ឧទា. ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៤៨ ជើងទំព័រ ១១៤, កថាខណ្ឌ ៥៥-៥៧, ៦០, ៦៣, ៦៧-៦៨, ៧១-៧២, ៧៥, ៨០-៨១។

[82] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៧៧ ជើងទំព័រ ១៦៩។ *សូមមើល រឿងក្តី រដ្ឋអាជ្ញា តទល់នឹង* Ntagerura *និងជនផ្សេងទៀត* សំណុំរឿងលេខ ICTR-99-46-A សាលក្រម ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ១៧៤ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៥ (ដោយសម្រេចថា "មានតែក្រោយពេលវិភាគទៅលើភ័ស្តុតាងពាក់ព័ន្ធទាំងអស់ប៉ុណ្ណោះ ដែលអង្គជំនុំជម្រះអាចសម្រេចថា តើភ័ស្តុតាងដែលអយ្យការបានយកមកសំអាង គួរតែត្រូវបានទទួលយកជាបានបង្ហាញនូវអត្ថិភាពនៃអង្គហេតុដែលបានចោទប្រកាន់ ឬយ៉ាងណា ថ្វីត្បិតតែមេធាវីការពារក្តីយកភ័ស្តុតាងនេះមកសំអាងក៏ដោយ។ នៅក្នុងដំណាក់កាលនៃការធ្វើសេចក្តីសន្និដ្ឋានលើអង្គហេតុនេះ ត្រូវអនុវត្តនូវបទដ្ឋាននៃការបង្ហាញភ័ស្តុតាងឲ្យហួសពីវិមតិសង្ស័យ ដើម្បីបង្ហាញអង្គហេតុដែលបង្កើតជាធាតុផ្សំនៃបទឧក្រិដ្ឋ ឬទម្រង់នៃការទទួលខុសត្រូវប្រឆាំងនឹងជនជាប់ចោទ ព្រមទាំង ពាក់ព័ន្ធនឹងអង្គហេតុនានាដែលមិនអាចខ្វះបានសម្រាប់ធ្វើការផ្តន្ទាទោស")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Stakić* សំណុំរឿងលេខ IT-97-24-A *សាលក្រម* ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ២១៩ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៦ (ដោយសម្រេចថា "អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទពីបទឧក្រិដ្ឋបាន តែក្នុងករណីដែលអយ្យការបានបង្ហាញនូវធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋនោះ (ដូចបានកំណត់ពាក់ព័ន្ធនឹងទម្រង់នៃការទទួលខុសត្រូវដែលពាក់ព័ន្ធ) ឲ្យហួសពីមតិសង្ស័យប៉ុណ្ណោះ។ បទដ្ឋាននេះអនុវត្តថា តើភ័ស្តុតាងដែលបានវាយតម្លៃនោះជាភ័ស្តុតាងផ្ទាល់ ឬប្រយោល។ នៅពេលមានការជំទាស់លើបណ្តឹងឧទ្ធរណ៍ ពាក់ព័ន្ធនឹងការសន្និដ្ឋានដើម្បីបង្ហាញអង្គហេតុមួយដែលជាមូលដ្ឋាននៃការផ្តន្ទាទោស បទដ្ឋាននេះត្រូវតែបំពេញឲ្យបាន ប្រសិនបើការសន្និដ្ឋាននោះមានភាពសមហេតុផលដែលទាញចេញពីភ័ស្តុតាងដែលបានដាក់បង្ហាញនោះ")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Blagojević និង Jokić* សំណុំរឿងលេខ IT-02-60-A *សាលក្រម* ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០០៧ កថាខណ្ឌ ២២៦ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៧ (ដោយសម្រេចថា "បទដ្ឋាននៃការបង្ហាញភ័ស្តុតាងនៅពេលជំនុំជម្រះតម្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទពីបទឧក្រិដ្ឋបាន តែក្នុងករណីដែលអយ្យការបានបង្ហាញនូវធាតុផ្សំនីមួយៗនៃបទឧក្រិដ្ឋនោះ និងទម្រង់នៃការទទួលខុសត្រូវ និង អង្គហេតុនានាដែលមិនអាចខ្វះបានសម្រាប់ការផ្តន្ទាទោស ឲ្យហួសពីមតិសង្ស័យប៉ុណ្ណោះ")។ *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Mrkšić និងជនផ្សេងទៀត* សំណុំរឿងលេខ IT-95-13/1-1-A *សាលក្រម* ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០០៩ កថាខណ្ឌ ២២០ ភ្ជាប់ក្នុងឧបសម្ព័ន្ធ ១៨ (ដោយសម្រេចថា "បទដ្ឋាននៃការបង្ហាញភ័ស្តុតាងនៅពេលជំនុំជម្រះតម្រូវថា អង្គជំនុំជម្រះសាលាដំបូងអាចរកឃើញពិរុទ្ធភាពរបស់ជនជាប់ចោទពីបទឧក្រិដ្ឋបាន តែក្នុងករណីដែលអយ្យការបានបង្ហាញនូវធាតុផ្សំ

របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើយុត្តាធិការបុគ្គល ត្រូវតែបំពេញទៅតាមបទដ្ឋាននៃការបង្ហាញភ័ស្តុតាងដែលអាចតម្រូវឲ្យមាន *ភ័ស្តុតាងបញ្ជាក់បន្ថែម* មុននឹងទទួលយកអង្គហេតុនីមួយៗ ថាមានការបញ្ជាក់ត្រឹមត្រូវ[83]។

## គ. សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញភ័ស្តុតាងខុសក្នុងការព្យាយាមធ្វើយុត្តិកម្មចំពោះកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ

41. ចុងក្រោយ នៅក្នុងចម្លើយតបទាំងមូលរបស់ខ្លួនទៅនឹងមូលដ្ឋានទី ៦ នៃបណ្តឹងឧទ្ធរណ៍ ជួនកាលសហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញភ័ស្តុតាងខុស ទាក់ទិននឹងការចោទប្រកាន់ពីតួនាទី និងការទទួលខុសត្រូវរបស់ អោ អាន នៅក្នុងតំបន់ ៤១ និង ភូមិភាគកណ្តាល ដើម្បីព្យាយាមធ្វើយុត្តិកម្មចំពោះកំហុសអង្គហេតុរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងចុងក្រោយផ្តល់យុត្តិកម្មដល់ការសម្រេចរបស់គាត់ទៅលើយុត្តាធិការបុគ្គល។

42. ឧទាហរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា ភ័ស្តុតាង "ពិតជាគាំទ្រការសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ដែលថា អោ អាន បានទទួលបញ្ជា និងសេចក្តីណែនាំពី កែ ពក" ដោយផ្អែកជាសំខាន់ទៅលើអត្ថបទដកស្រង់ពីសារព័ត៌មានដែលបានសម្ភាស អោ អាន ដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានលុបផ្នែកសំខាន់មួយចោល[84]។ នៅក្នុងឱកាសមួយ សហព្រះរាជអាជ្ញាអន្តរជាតិ បានអះអាងថា "ភ័ស្តុតាងយ៉ាងច្រើនសន្ធឹកសន្ធាប់របស់សាក្សី [ប្រាក់] យុត" ទាក់ទិននឹងអ្នកនៅក្រោមបង្គាប់ អោ អាន "ត្រូវបានបញ្ជាក់បន្ថែមយ៉ាងរឹងមាំ" ដោយសាក្សីផ្សេងៗទៀត[85]។ តាមការពិត សាក្សីផ្សេងៗទៀតទាំងនេះត្រឹមតែនិយាយអំពីការប្រជុំប៉ុណ្ណោះ មិនបាននិយាយពីការរាយការណ៍ទេ ហើយពួកគេភាគច្រើនមិនបានដឹងពីខ្លឹមសារនៃការប្រជុំទាំងនោះ

---

នីមួយៗនៃបទឧក្រិដ្ឋនោះ និងទម្រង់នៃការទទួលខុសត្រូវ និង អង្គហេតុនានាដែលមិនអាចខ្វះបានសម្រាប់ការផ្តន្ទាទោសឲ្យហួសពីមតិសង្ស័យប៉ុណ្ណោះ")។

[83] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៥៥ ជើងទំព័រ ៩៧-៩៨។

[84] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦០ ជើងទំព័រ ១៤៩ (ស.ព.អ បានយោងទៅឯកសារ **D103.1.39** (បទសម្ភាសន៍ អោ អាន ជាមួយនឹងវិទ្យុសម្លេងសហរដ្ឋអាមេរិកជាភាសាខ្មែរ) តែគាត់បានលប់ចោលផ្នែកសំខាន់មួយ។ នៅក្នុងបទសម្ភាសន៍នោះ អោ អាន បានលើកឡើងថា ទោះបី កែ ពក បានបញ្ជាឲ្យគាត់សម្លាប់អ្នកគាំទ្ររបស់ លន់ នល់ ក៏ដោយ តែគាត់មិនបានធ្វើការបញ្ជាទាំងនេះទេ ផ្ទុយទៅវិញ គាត់បានលាក់បំពួនអ្នកទាំងនោះនៅតាមវាលស្រែ)។

[85] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦៨។

ឡើយ[86]។ ចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ ជំទាស់ថា "វាពិតជា សមហេតុសមផល" សម្រាប់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការសន្និដ្ឋានថា អោ អាន គឺជាអនុលេខាភូមិភាគកណ្តាល[87]។ ក៏ប៉ុន្តែ នៅក្នុងការវិភាគរបស់ខ្លួន សហព្រះរាជអាជ្ញាអន្តរជាតិ មិនចាប់អារម្មណ៍ដល់ភ័ស្តុតាងដោះបន្ទុកសំខាន់ៗដែលមេធាវីការពារក្តីបានរកឃើញដែលបង្ហាញថា អោ អាន មិនបានកាន់តំណែងនេះទាំងតាមផ្លូវច្បាប់ ឬតាមសភាពជាក់ស្តែងឡើយ[88]។

43. ហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបដិសេធការអះអាងរបស់មេធាវីការពារក្តីដែលថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពិតជាមានកំហុស ក្នុងការសន្និដ្ឋានថា អោ អាន ស្ថិតក្នុងចំណោម "អ្នកទទួលខុសត្រូវខ្ពស់បំផុត" នោះឡើយ។

## V. សារណាតបចំពោះចម្លើយតបទៅនឹងមូលដ្ឋានទី ៧ នៃបណ្តឹងឧទ្ធរណ៍៖ សហព្រះរាជអាជ្ញាអន្តរជាតិ បន្ទោរ និងរំលងការចង់បានរបស់ខ្លួននូវទស្សនៈដែលលើកឡើងដោយ អោ អាន អំពីកំហុសអង្គហេតុ និងអង្គច្បាប់របស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទាក់ទិននឹងស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលបានចោទប្រកាន់

44. សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញភ័ស្តុតាងគាំទ្រដល់ការអះអាងរបស់ខ្លួនដែលថា មេធាវីការពារក្តី "ខកខានមិនបានបង្ហាញថា ឧក្រិដ្ឋកម្មដែលរូបគាត់ត្រូវបានចោទប្រកាន់នោះ មិន

---

[86] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៦៨ ជើងទំព័រ ១៧៣-១៧៤ (សាក្សីនានាដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានដកស្រង់ ត្រឹមតែផ្តល់ភ័ស្តុតាងពាក់ព័ន្ធនឹងការចូលរួមប្រជុំរបស់ អោ អាន ប៉ុណ្ណោះ។ ពួកគេជាច្រើនមិនបានដឹងថាការប្រជុំទាំងនោះអំពីបញ្ហាអ្វី ឬនិយាយពីអ្វីទេ។ ពុត កុល រាយការណ៍ថា បានឃើញ អោ អាន និយាយជាមួយ ប្រាក់ យុត តែលើកឡើងថា គាត់មិនបានដឹងថា ពួកគេនិយាយពីអ្វីទេ។ សាត ភាព ក៏បានរាយការណ៍ថា អោ អាន បានចូលរួមការប្រជុំប្រចាំថ្ងៃ តែគាត់ត្រឹមតែដឹងពីព័ត៌មាននេះប៉ុណ្ណោះ តែគាត់បានឃើញ អោ អាន ជិះឡានចេញ។ ពុំមានភាពច្បាស់ថា តើ សាត ភាព បានដឹងថា អោ អាន ជិះឡានចេញទៅប្រជុំ ក្រៅពីទៅកន្លែងផ្សេងទៀត ដោយរបៀបណាទេ។ អ៊ឹម ប៊ុន បានផ្តល់ព័ត៌មានថា អោ អាន បានទៅពិនិត្យការដ្ឋានការងារ គាត់ជាអ្នកគ្រប់គ្រងការសាងសង់ទំនប់ និង គាត់បានប្រជុំជាមួយប្រធាន។ ក៏ប៉ុន្តែ ព័ត៌មាននេះបានមកពីព័ត៌មានដែលអ្នកស៊ើបអង្កេតនៅក្នុងការិយាល័យសហចៅក្រមស៊ើបអង្កេត ផ្តល់ឲ្យ អ៊ឹម ប៊ុន ប៉ុណ្ណោះ។ ស្រដៀងគ្នាដែរ យូ វ៉ាន់ បានលើកឡើងថា គាត់បានបញ្ជូនសំបុត្រពី ប្រាក់ យុត តែគាត់មិនបានលើកឡើងពីខ្លឹមសារនៅក្នុងសំបុត្រទាំងនេះទេ)។

[87] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៨៣។

[88] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៩៣-១៤៥។

មានទម្ងន់គ្រប់គ្រាន់ដើម្បីដាក់រូបគាត់ឲ្យស្ថិតក្នុងយុត្តាធិការបុគ្គលរបស់ អ.វ.ត.ក"[89] នោះឡើយ។ ផ្ទុយទៅនឹងការចូលរួមយ៉ាងពេញលេញនៅក្នុងទឡ្ហីករណ៍របស់មេធាវីការពារក្ដី សហព្រះរាជអាជ្ញាអន្តរជាតិ បង្ខូរ និងរើសយកតាមការចង់បានរបស់ខ្លួននូវផ្នែកខ្លះនៃទឡ្ហីករណ៍ទាំងនោះ[90]។ គាត់បានអះអាងដោយមិនត្រឹមត្រូវថា កត្តានានាដូចជា ដែនកំណត់ភូមិសាស្ត្រ និងចំនួនជនរងគ្រោះ មិនសូវសំខាន់ជាងស្ថានទម្ងន់នៃបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទេ ហើយថា អំពើប្រល័យពូជសាសន៍នៅក្នុងតំបន់ ៤២ និងតំបន់ ៤៣ អាចសន្និដ្ឋានបាន និងកើតឡើងដោយសារតែ អោ អាន។ អំណះអំណាងទាំងនេះផ្ទុយពីយុត្តិសាស្ត្រពីមុនរបស់ អ.វ.ត.ក[91]។ ការវិភាគរបស់មេធាវីការពារក្ដីនៅក្នុង *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* គឺផ្អែកទៅលើយុត្តិសាស្ត្រនេះ។

45. ហេតុនេះ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបដិសេធអង្គហេតុដែលថា ភ័ស្តុតាងដែល សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានផ្ដល់ ស្ទើរតែទាំងអស់បានមកពីតំបន់ ៤១ ដែលជាទីតាំងភូមិសាស្ត្រតូចមួយ ថាពុំមានភ័ស្តុតាងគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការគណនារបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ទៅលើចំនួនជនរងគ្រោះនៅក្នុងភូមិភាគកណ្ដាល ឬតំបន់ ៤១ ឬថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនអាចដាក់ការចោទប្រកាន់ពីចំនួនជនរងគ្រោះមកពីតំបន់ ៤២ និងតំបន់ ៤៣ ទៅលើ អោ អាន តាមរយៈទម្រង់នៃការទទួលខុសត្រូវដែលបានចោទប្រកាន់ឡើយ[92]។

## VI. ការឆ្លើយតបចំពោះចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅលើមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ៨, ៩, ១១, ១២, ១៤, ១៥ និង ១៦(១) ÷ សហព្រះរាជអាជ្ញាអន្តរជាតិខកខានមិនបានបដិសេធនៅលើកំហុសឆ្គងអង្គច្បាប់ ដែលមេធាវីការពារក្ដីបានកំណត់ ទាក់ទងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការសម្រេច និងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[89] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៨៩។

[90] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩០។

[91] *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ៥០ ជើងទំព័រ ៨៦។ *សេចក្ដីពិចារណាលើបណ្ដឹងឧទ្ធរណ៍ក្នុងសំណុំរឿង ០០៤/១* កថាខណ្ឌ ៣២៧-៣២៨។ *ដីកាសម្រេចលើកលែងការចោទប្រកាន់* កថាខណ្ឌ ៤២៨។ *សាលដីកាសំណុំរឿង ០០១* កថាខណ្ឌ ៦២។

[92] *បណ្ដឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៥៧-១៦២។

46. ពាក់ព័ន្ធមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ ៨, ៩, ១១, ១២, ១៤, ១៥ និង ១៦(១) សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងថា មេធាវីការពារក្ដីមិនបានបង្ហាញពីកំហុសអង្គច្បាប់ពាក់ព័ន្ធនឹងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រាប់ការសម្រេច និងការអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ[93]។ ទោះជាយ៉ាងនេះក្ដី នៅពេលធ្វើការអះអាងបែបនេះ សហព្រះរាជអាជ្ញាអន្តរជាតិ (ក) មិនបានគិតអំពីភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបង្ហាញឲ្យបានគ្រប់គ្រាន់ពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានយោងក្នុង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* និង (ខ) មិនពិចារណាអំពីសារៈសំខាន់នៃការត្រួតពិនិត្យទៅលើប្រភពផ្សេងទៀតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្រៅពីយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច។ ជាលទ្ធផល សហព្រះរាជអាជ្ញាអន្តរជាតិមិនបានបដិសេធមូលដ្ឋានបណ្ដឹងឧទ្ធរណ៍ទាំងអស់ ដែលបណ្ដាលមកពីវិធីសាស្ត្រមានកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

### ក. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានគិតអំពីភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបង្ហាញឲ្យបានគ្រប់គ្រាន់ពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ

47. សហព្រះរាជអាជ្ញាអន្តរជាតិមិនបានគិតអំពីភារកិច្ចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការបង្ហាញឲ្យបានគ្រប់គ្រាន់ពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានពឹងផ្អែកលើក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។ នៅក្នុងការអនុវត្តបែបនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងដោយខុសឆ្គងថា មេធាវីការពារក្ដីមិនបានកំណត់អំពីកំហុសឆ្គងនៅក្នុងការប្រើប្រាស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ[94]។ សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងបន្ថែមថា ដើម្បីបង្ហាញពីកំហុសឆ្គងរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុងការពឹងផ្អែកទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ មេធាវីការពារក្ដីត្រូវតែពឹងបង្ហាញភស្តុតាងពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ

[93] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩២-៩៣, ៩៥-៩៦, ៩៩-១០១, ១០៥។

[94] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩២-៩៣, ៩៥-៩៦, ៩៩-១០១, ១០៥។

ដែលផ្ទុយពីនេះ[95]។

48. ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញាអន្តរជាតិ មេធាវីការពារក្តីបានកំណត់អំពីកំហុសឆ្គងអង្គច្បាប់យ៉ាងច្បាស់នៅក្នុងវិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិសម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលបានរំលោភបំពានទៅលើគោលការណ៍នីត្យានុកូលភាព[96]។ នៅក្នុង *ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* ទាំងមូល សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានពឹងផ្អែកជាចម្បងទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាមូលដ្ឋានគតិយុត្តិសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ[97] ដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិត្រូវតែបង្ហាញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិនេះមានអត្ថិភាពនៅក្នុងអំឡុងឆ្នាំ ១៩៧៥ ដល់ឆ្នាំ១៩៧៩[98] ប៉ុន្តែ គាត់បែរជាមិនបានបង្ហាញទៅវិញ។ ផ្ទុយទៅវិញ សហចៅក្រមស៊ើបអង្កេតអន្តរជាតិបានអនុវត្តវិធីសាស្ត្រដែលមានកំហុសឆ្គងក្នុងការបកស្រាយ និងអនុវត្តច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលការអនុវត្តបែបនេះធ្វើឲ្យប៉ះពាល់ដល់គោលការណ៍នីត្យានុកូលភាព[99]។ ដូចដែលបានបញ្ជាក់នៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ទាក់ទងនឹងការសម្រេចផ្នែកគតិយុត្តិមួយចំនួនរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានបកស្រាយ និងអនុវត្តដោយខុសឆ្គងនូវច្បាប់ទំនៀមទម្លាប់អន្តរជាតិដោយ (ក) មិនបានគោរពតាមបទដ្ឋាននៃការបង្ហាញភស្តុតាងដែលត្រឹមត្រូវដែលបានតម្រូវសម្រាប់ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ជាពិសេសមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់អំពីការអនុវត្តរបស់រដ្ឋ[100] (ខ) ពឹងផ្អែកខ្លាំងពេកទៅលើយុត្តិសាស្ត្ររបស់អង្គជំនុំជម្រះចំពោះ

[95] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៣, ៩៦, ១០០-១០១, ១០៥។

[96] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៦-១៧៤, ១៧៨-១៨១, ១៨៧-១៩៣, ១៩៦។

[97] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ៦៣-១២០។

[98] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៧ (កត់សម្គាល់លើលក្ខខណ្ឌតម្រូវនៅក្នុងច្បាប់អន្តរជាតិសម្រាប់ការកំណត់អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

[99] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៦-១៧០។

[100] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៧-១៦៨, ១៧២-១៧៣, ១៧៨-១៨១, ១៨៧-១៨៨, ១៩០-១៩៣, ១៩៦ ជើងទំព័រ ៤១៩( បង្ហាញថា ស.ច.ស.អ មិនបានបង្ហាញភស្តុតាងគ្រប់គ្រាន់អំពីការអនុវត្តរបស់រដ្ឋ និងទស្សនៈច្បាប់ដើម្បីបញ្ជាក់ពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងគូសបញ្ជាក់ពីឧទាហរណ៍អំពីការកំណត់របស់ ស.ច.ស.អ ដែលមានសំអាងហេតុមិនគ្រប់គ្រាន់ និងមិនត្រឹមត្រូវអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដោយសារខ្វះភស្តុតាងបញ្ជាក់ពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ)។

កិច្ច[101] និង (គ) មិនបានពិចារណាលើភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលពាក់ព័ន្ធ ដូចជាច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ[102]។ នេះគឺជាកំហុសឆ្គងអង្គច្បាប់យ៉ាងច្បាស់ក្រឡែត ដែលសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានលើកឡើងនៅក្នុងចម្លើយតបរបស់គាត់។

49. លើសពីនេះទៀត នៅក្នុង*ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* សហព្រះរាជអាជ្ញាអន្តរជាតិបានអះអាងជាច្រើនដងថា មិនមានកំហុសឆ្គងអង្គច្បាប់ជាក់ស្តែងឡើយ លើកលែងតែមេធាវីការពារក្តីបង្ហាញពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលផ្ទុយពីនេះ ហើយការសម្រេចលើច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បើទោះបីជាមិនមានសំអាងហេតុគ្រប់គ្រាន់ ឬមិនត្រឹមត្រូវក៏ដោយ ក៏ត្រូវតែតម្កល់ដែរ[103]។ ទឡ្ហីករណ៍នេះបង្ហាញអំពីការមិនគិតពិចារណាទៅលើគោលការណ៍នីត្យានុកូលភាព និងចេតនាក្នុងការកែប្រែបន្ទុកក្នុងការបង្ហាញភស្តុតាងឲ្យទៅជាបន្ទុករបស់មេធាវីការពារក្តីវិញ។ បន្ទុកក្នុងការបង្ហាញភស្តុតាងរបស់មេធាវីការពារក្តីត្រូវបានកម្រិតត្រឹមតែលើការបង្ហាញពីកំហុសឆ្គងអង្គច្បាប់ ហើយមេធាវីការពារក្តីមិនមានបន្ទុកក្នុងការបង្ហាញពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែលផ្ទុយឡើយ[104]។ ជាការគ្រប់គ្រាន់

---

[101] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៦-១៧៤, ១៧៨, ១៨១, ១៩៦ ( ពិភាក្សាបញ្ហានានាដែលពឹងផ្អែកលើ យុត្តិសាស្ត្រសាលាក្តីពិសេស ជាភស្តុតាងបញ្ជាក់ពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងផ្តល់ឧទាហរណ៍អំពីការពឹងផ្អែកហួសហេតុរបស់ ស.ច.ស.អ លើយុត្តិសាស្ត្របែបនោះ)។

[102] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៩, ១៧៣, ១៨១, ១៩០-១៩១, ១៩៦ (ផ្តល់ឧទាហរណ៍អំពីភស្តុតាងបញ្ជាក់ពីច្បាប់ទំនៀមទម្លាប់អន្តរជាតិដែល ស.ច.ស.អ មិនបានពិចារណា)។

[103] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៣, ៩៦, ១០០-១០១, ១០៥។

[104] ជាកាតព្វកិច្ចរបស់ ស.ច.ស.អ ដែលត្រូវបង្ហាញភស្តុតាងឲ្យបានគ្រប់គ្រាន់អំពីអត្ថិភាពនៃទំនៀមទម្លាប់ច្បាប់អន្តរជាតិនៅឆ្នាំ ១៩៧៥-១៩៧៩។ គោលការណ៍ *iura novit curia* (តុលាការដឹងច្បាប់)អនុវត្តនៅក្នុងច្បាប់អន្តរជាតិ។ *សំណុំរឿងពាក់ព័ន្ធនឹងសកម្មភាពយោធា និងប៉ារ៉ាមីលីធែរនៅក្នុងប្រទេសនីការ៉ាហ្គា និងប្រឆាំងនឹងនីការ៉ាហ្គា (នីការ៉ាហ្គា តទល់នឹងសហរដ្ឋអាមេរិក) សាលក្រម* 1986 ICJ 14 កថាខណ្ឌ ២៩ ភ្ជាប់ជាឧបសម្ព័ន្ធ ១៩។ *រឿងក្តី ដែនយុត្តាធិការនេសាទ (សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ តទល់នឹងអាយស៍ឡែន) សាលក្រម* កថាខណ្ឌ ១៨ *ភ្ជាប់ជាឧបសម្ព័ន្ធ* ២០ (សម្រេចថា "ដោយសារជាភារកិច្ចរបស់តុលាការដែលត្រូវបញ្ជាក់ និងអនុវត្តច្បាប់ដែលពាក់ព័ន្ធនៅក្នុងកាលៈទេសៈនានានៃរឿងក្តី ទើបបន្ទុកក្នុងការកំណត់ ឬបញ្ជាក់អំពីវិធាននានានៅក្នុងច្បាប់អន្តរជាតិមិនអាចដាក់លើភាគីណាមួយទេ ពីព្រោះថា ច្បាប់ស្ថិតនៅក្នុងក្របខណ្ឌចំណេះដឹង របស់តុលាការ"។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Milutinović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-97-PT *សេចក្តីសម្រេចលើសំណើរបស់ Ojdanic ជំទាស់នឹងយុត្តាធិការ៖ សហចារីមិនផ្ទាល់* ថ្ងៃទី២២ ខែមីនា ឆ្នាំ២០០៦ កថាខណ្ឌ ១៦ ភ្ជាប់ជាឧបសម្ព័ន្ធ ២១("សម្រេចថា ជាបញ្ហាបឋមចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា មិនមានមូលដ្ឋានទេចំពោះទឡ្ហីករណ៍នៅក្នុងចម្លើយតបរបស់

សម្រាប់មេធាវីការពារក្តីក្នុងការបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានផ្តល់ភស្តុតាងគ្រប់គ្រាន់សម្រាប់ការដែលគាត់បានពឹងផ្អែកទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាអំពីការបកស្រាយលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ តាមជម្រើសផ្សេងដែលសមហេតុផល។

**ខ. សហព្រះរាជអាជ្ញាអន្តរជាតិមិនពិចារណាអំពីសារៈសំខាន់នៃការត្រួតពិនិត្យទៅលើប្រភពផ្សេងៗទៀតនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ ក្រៅពីយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច**

50. សហព្រះរាជអាជ្ញាអន្តរជាតិបានរិះគន់ដោយខុសឆ្គងចំពោះការពឹងផ្អែករបស់មេធាវីការពារក្តីទៅលើច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ថាជាភស្តុតាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ការរិះគន់បែបនេះគឺថា សហព្រះរាជអាជ្ញាអន្តរជាតិមិនបានគិតដល់*គោលការណ៍សម្រាល (lex mitior)* ហើយបានវិភាគដោយខុសឆ្គងទៅលើគោលបំណងរបស់មេធាវីការពារក្តីក្នុងការពឹងផ្អែកទៅលើប្រភពផ្សេងៗនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

51. ជាបឋម សហព្រះរាជអាជ្ញាអន្តរជាតិបានជំទាស់យ៉ាងខ្លាំងទៅនឹងការដែលមេធាវីការពារក្តីប្រើប្រាស់ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបានតាក់តែងឡើងជាក្រម នៅក្រោយឆ្នាំ១៩៧៩ ធ្វើជាភស្តុតាងសម្រាប់បង្ហាញថា ច្បាប់ទំនៀមទម្លាប់អន្តរជាតិអាចអនុវត្តបាននៅតុលាការនេះ[105]។ ទោះជាយ៉ាងនេះក្តី បើយោងតាមគោលការណ៍សម្រាល ជាការចាំបាច់ដែលត្រូវពិនិត្យមើលការវិវឌ្ឍន៍នៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងច្បាប់កម្ពុជា ដែលបានកើតឡើងតាំងពីឆ្នាំ១៩៧៩។ ប្រសិនបើមានការវិវឌ្ឍន៍នៃច្បាប់ជាធរមាន បន្ទាប់ពីការកើតឡើងនៃបទល្មើស ហើយការវិវឌ្ឍន៍

---

Ojdanic ត្រង់ចំណុចដែលថា "អយ្យការមានបន្ទុកត្រូវបង្ហាញថា ទម្រង់នៃការទទួលខុសត្រូវជាសហចារីមិនផ្ទាល់"មាននៅក្នុងទំនៀមទម្លាប់ច្បាប់អន្តរជាតិនៅឆ្នាំ១៩៩៩"។ ការជំទាស់របស់ Ojdanic លើបញ្ហាយុត្តាធិការ គឺជាបញ្ហាអង្គច្បាប់ដែលត្រូវសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង មិនមែនជាបញ្ហាអង្គហេតុដែលភាគីណាមួយមានបន្ទុកត្រូវបង្ហាញនោះទេ ទោះបីជាថាទឡ្ហីករណ៍របស់ភាគីពិតជាអាចជួយអង្គជំនុំជម្រះក្នុងការវាយតម្លៃលើការជំទាស់បែបនេះក៏ដោយ")។

[105] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៣, ៩៦, ១០១, ១០៥។ មេធាវីការពារក្តី ក៏កត់សម្គាល់ផងដែរលើចំណុចផ្ទុយគ្នានៅក្នុងទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដែលថា ច្បាប់របស់តុលាការព្រហ្មទណ្ឌអន្តរជាតិ មិនគួរត្រូវចាត់ទុកថាអាចយកមកអនុវត្តបានទេ ពីព្រោះថា ច្បាប់នេះត្រូវបានរៀបចំឡើងក្រោយឆ្នាំ១៩៧៩ ដោយពិនិត្យមើលការសង្កត់ធ្ងន់យ៉ាងខ្លាំងលើយុត្តាធិការសាលាក្តីនៅក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* របស់ ស.ច.ស.អ។

នោះបានជាប្រយោជន៍ដល់ជនជាប់ចោទ ជាការចាំបាច់ត្រូវអនុវត្តច្បាប់ដែលស្រាលជាង[106]។ ហេតុដូច្នេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិគួរតែបានពិចារណាទៅលើការវិវឌ្ឍន៍ថ្មីៗនៃច្បាប់ ដើម្បីវាយតម្លៃថាតើការវិវឌ្ឍន៍បែបនេះតំណាងឲ្យបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ហើយបានជាប្រយោជន៍ដល់ជនជាប់ចោទដែរឬទេ។ សំខាន់បំផុតនោះ ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិតំណាងឲ្យការតាក់តែងជាក្រមនៃបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលមានអត្ថិភាពតាំងពីមុនលក្ខន្តិកៈទីក្រុងរ៉ូម ដែលកម្ពុជាបច្ចុប្បន្ននេះ គឺជាភាគីហត្ថលេខីនៃលក្ខន្តិកៈទីក្រុងរ៉ូមនេះ[107]។ មេធាវីការពារក្តីបានផ្តល់ឧទាហរណ៍នៃច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ និង/ឬ ដែលផ្តល់ជាប្រយោជន៍ជាងដល់ជនជាប់ចោទ ហើយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនបានអនុវត្តនៅក្នុងសំណុំរឿង អោ អាន[108]។ ហេតុដូច្នេះ មេធាវីការពារក្តីបានបង្ហាញពីកំហុសអង្គច្បាប់របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ។

52. ទីពីរ សហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងករណីថា មេធាវីការពារក្តីមិនបានបង្ហាញថា ច្បាប់

[106] គោលការណ៍យកច្បាប់ដាក់ទោសស្រាល អាចអនុវត្តបាននៅ អ.វ.ត.ក ហើយជាទំនៀមទម្លាប់ច្បាប់អន្តរជាតិ។ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក *សាលដីកា* ឯកសារ **F36** ថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ៥៧៩, ៥៨៥ ភ្ជាប់ជាឧបសម្ព័ន្ធ ២២។ សំណុំរឿង ០០៣/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស *ការជូនដំណឹងស្តីពីការបកស្រាយ "ការវាយប្រហារទៅលើប្រជាជនស៊ីវិល" នៅក្នុងបរិបទនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ទាក់ទងទៅនឹងកងកម្លាំងប្រដាប់អាវុធផ្ទាល់របស់របបឬរដ្ឋនោះ* ឯកសារ **D306/17.1** ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០១៧ កថាខណ្ឌ ១៦ ភ្ជាប់ជាឧបសម្ព័ន្ធ ២៣។ Royaume Du Cambodge Code Pénal et Lois Penales (ឆ្នាំ១៩៥៦) (ប្រទេសកម្ពុជា) មាត្រា ៦ ភ្ជាប់ជាឧបសម្ព័ន្ធ ២៤។ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ 999 UNTS 171 អនុម័តថ្ងៃទី១៩ ខែធ្នូ ឆ្នាំ១៩៦៦ មាត្រា ១៥(១)។ *សូមមើលផងដែរ* រឿងក្តី *រឿងក្តីតទល់នឹង Deronjić* សំណុំរឿងលេខ IT-02-61-A *សាលដីកាលើបណ្តឹងសាទុក្ខដាក់ទោស* ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៥ កថាខណ្ឌ ៩៦-៩៧ ភ្ជាប់ជាឧបសម្ព័ន្ធ ២៥។

[107] ភាគី និងហត្ថលេខីនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ភ្ជាប់ជាឧបសម្ព័ន្ធ ២៦។ រឿងក្តី រដ្ឋអាជ្ញាតទល់នឹង *Duško Tadić* សំណុំរឿងលេខ*IT-94-1-A* *សាលក្រម* ថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៩ កថាខណ្ឌ ២២៣ ភ្ជាប់ជាឧបសម្ព័ន្ធ ២៧ *(សម្រេចថា '[លក្ខន្តិកៈទីរ៉ូម] ត្រូវបានអនុម័តដោយរដ្ឋច្រើនលើសលុបដែលបានចូលរួមសន្និសីទការទូតទីក្រុងរ៉ូម ហើយក៏ទទួលបានការឯកភាពយ៉ាងច្រើនពីគណៈកម្មាធិការទី ៦ នៃមហាសន្និបាតអង្គការសហប្រជាជាតិ*។ នេះបង្ហាញថា ខ្លឹមលក្ខន្តិកៈនោះត្រូវបានរដ្ឋយ៉ាងច្រើនគាំទ្រ ហើយអាចប្រើប្រាស់ដើម្បីបង្ហាញពីគោលជំហរអង្គច្បាប់ គឺទស្សនៈច្បាប់របស់រដ្ឋទាំងនោះ')។ រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង Krnojelac* សំណុំរឿងលេខ IT-97-25-A *សាលក្រម* ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០៣ កថាខណ្ឌ ២២១ ភ្ជាប់ជាឧបសម្ព័ន្ធ ២៨ (សម្រេចថា លក្ខន្តិកៈទីក្រុងរ៉ូម ឆ្លុះបញ្ចាំងពីការអនុវត្តរបស់រដ្ឋ)។

[108] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៣, ១៧៩, ១៨១, ១៩០-១៩១, ១៩៦។

តុលាការព្រហ្មទណ្ឌអន្តរជាតិផ្ទុះបញ្ចាំងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[109]។ ជាថ្មីម្តងទៀត ទ ឡើករណ៍នេះបានកំណត់ដោយខុសឆ្គងពីបន្ទុកទៅលើមេធាវីការពារក្តីក្នុងការបង្ហាញភស្តុតាងនៃ ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដូចដែលបានបដិសេធពីខាងលើ។ លើសពីនេះទៀត សហព្រះរាជ អាជ្ញាអន្តរជាតិបានយល់ច្រឡំលើសំអាងហេតុពេញលេញនៃការដែលមេធាវីការពារក្តីពឹងផ្អែកទៅ លើច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិ នៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន*។ សហចៅក្រម ស៊ើបអង្កេតអន្តរជាតិមិនបានពិចារណាឲ្យបានគ្រប់គ្រាន់ទៅលើប្រភពនៃភស្តុតាងរបស់ច្បាប់ ទំនៀមទម្លាប់អន្តរជាតិផ្សេងៗទៀត ដូចជា ច្បាប់តុលាការព្រហ្មទណ្ឌអន្តរជាតិជាដើម[110]។ ដោយ សារលក្ខន្តិកៈទីក្រុងរ៉ូមតំណាងឲ្យការតាក់តែងក្រមនៃបទដ្ឋានច្បាប់ទំនៀមទម្លាប់អន្តរជាតិ បើ ទោះបីជាច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនបានឈានដល់ឋានៈជាច្បាប់ទំនៀមទម្លាប់អន្តរជាតិដែល មិនមានការជំទាស់ក្តី ត្រឹមតែវត្តមានរបស់ច្បាប់នេះ រួមជាមួយការដាកចេញពីយុត្តិសាស្ត្ររបស់ តុលាការចំពោះកិច្ច (និងការអះអាងដទៃៗទៀតអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ) ក៏អាចបណ្តាល ឲ្យមានការចោទសួរអំពីសុពលភាពនៃការអះអាងអំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិរបស់សហ ចៅក្រមស៊ើបអង្កេតអន្តរជាតិ ដោយពិចារណាថា ការអះអាងទាំងអស់នេះពឹងផ្អែកជាចម្បងទៅ លើយុត្តិសាស្ត្ររបស់តុលាការចំពោះកិច្ច។ មេធាវីការពារក្តីពឹងផ្អែកទៅលើច្បាប់តុលាការព្រហ្ម ទណ្ឌអន្តរជាតិ នៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ទាំងមូល ដើម្បីបញ្ជាក់ពីការបកស្រាយផ្សេ ងៗទៅលើច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលដូចគ្នា[111] បើទោះបីជាមិនផ្តល់ជាប្រយោជន៍ជាង[112] ច្បាប់ទំនៀមទម្លាប់អន្តរជាតិទាំងឡាយ ដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកឡើង។ នៅក្នុងការធ្វើដូច្នេះ មេធាវីការពារក្តីបានកំណត់អំពីកំហុសអង្គច្បាប់របស់សហចៅក្រមស៊ើប អង្កេតអន្តរជាតិ។

## VI. ការឆ្លើយតបចំពោះចម្លើយរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅលើមូលដ្ឋានទី ១០ នៃ ប

---

[109] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៣, ៩៦, ១០១, ១០៥។

[110] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៩, ១៧៣, ១៧៩, ១៨១, ១៩០-១៩១, ១៩៦។

[111] យល់ឃើញថា ទាំងសាលាក្តីពិសេស ទាំងតុលាការព្រហ្មទណ្ឌអន្តរជាតិត្រូវបានបង្កើតឡើងក្រោយឆ្នាំ១៩៧៩។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៨។

[112] ផ្ទុយពីសាលាក្តីពិសេស សហគមន៍អន្តរជាតិបានចូលរួមធ្វើវិធានព្រហ្មទណ្ឌនានានៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម ដែលត្រូវបាន អនុម័តជាផ្លូវដោយរដ្ឋជាច្រើន រួមទាំងកម្ពុជា ផងដែរ។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦៨-១៦៩។

**បណ្តឹងឧទ្ធរណ៍ ÷ សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបង្ហាញថា កម្រិតនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានកំណត់ និងអនុវត្តដោយត្រឹមត្រូវនោះទេ**

53. ជាការឆ្លើយតបចំពោះមូលដ្ឋានទី១០ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានលើកឡើងអំពីកំហុសឆ្គងដែលបានកំណត់នៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ទាក់ទងនឹងការសម្រេចរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្តីពីសមាជិកភាពនៃក្រុមសហឧក្រិដ្ឋកម្មរួម វិសាលភាពភូមិសាស្ត្រ និងគោលបំណងរួម។

54. ទីមួយ សហព្រះរាជអាជ្ញាអន្តរជាតិមិនបានពន្យល់ថាតើ ការបរិយាយរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីក្រុមសហឧក្រិដ្ឋកម្មរួម អាចត្រូវបានចាត់ទុកថាច្បាស់លាស់គ្រប់គ្រាន់ដែរឬយ៉ាងណា[113]។ លើសពីនេះទៀត សហព្រះរាជអាជ្ញាអន្តរជាតិមានចេតនាបញ្ជាក់អំពីសមាជិកភាពក្រុមសហឧក្រិដ្ឋកម្មរួម ដោយផ្តល់"បញ្ជីលម្អិតស្តីពីកម្មាភិបាលមួយចំនួន ដែលស្ថិតក្នុងប្រភេទនេះ"[114]។ នៅក្នុងការធ្វើដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិបានធ្វើឱ្យច្របូកច្របល់បន្ថែមទៀតទៅលើបញ្ហានេះ។ "បញ្ជីលម្អិត" នេះ រួមបញ្ចូលចាប់ពី ប៉ុល ពត រហូតដល់អ្នកបើកឡានរបស់ អោ អាន និងអ្នករាល់គ្នាដែលនៅចន្លោះនេះ[115]។ ក្រុមសហឧក្រិដ្ឋកម្មរួមសរុបនេះរឹតតែមានភាពទូលំទូលាយជាងក្រុមមួយដែលសហចៅក្រមស៊ើបអង្កេតអន្តរជាតិបានលើកស្នើឡើង។ ទោះបីជាសហចៅក្រមស៊ើបអង្កេតអន្តរជាតិមិនត្រូវបានតម្រូវឱ្យកំណត់អត្តសញ្ញាណជាឈ្មោះសម្រាប់សមាជិកសហឧក្រិដ្ឋកម្មរួមនីមួយៗក្តី ប៉ុន្តែ ទាំងសហចៅក្រមស៊ើបអង្កេតអន្តរជាតិ និងសហព្រះរាជអាជ្ញាអន្តរជាតិ មិនបានកំណត់អត្តសញ្ញាណឱ្យបានគ្រប់គ្រាន់ពីក្រុមសហឧក្រិដ្ឋកម្មរួមមួយដែលមានមុខងារជាក់ស្តែង ដែលមានគោលបំណងរួមដូចគ្នាឡើយ[116]។

---

[113] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤។ ផ្ទុយមកវិញ *សូមមើល បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៥។

[114] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤ (គូសបញ្ជាក់បន្ថែម) (ដកស្រង់សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *ដីកាសន្និដ្ឋានស្ពាពររបស់សហព្រះអាជអាជ្ញាអន្តរជាតិអនុលោមតាមវិធាន ៦៦ នៃវិធានផ្ទៃក្នុង ("ដីកាសន្និដ្ឋានស្ពាពរ")*ឯកសារ **D351/5** ថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៧ កថាខណ្ឌ ៦៧៥)។

[115] *ដីកាសន្និដ្ឋានស្ពាពរ* កថាខណ្ឌ ៦៧៥។

[116] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៥។

55. ចំណុចទី២ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានតវ៉ាអំពីការខកខានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបានកំណត់វិសាលភាពភូមិសាស្ត្រនៃសហឧក្រិដ្ឋកម្មរួម ស្របតាមអង្គហេតុនៃរឿងក្តី[117]។ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានពន្យល់ថាតើបទចោទនៅក្នុង*កំណត់ហេតុនៃការបង្ហាញខ្លួនម្តងទៀត* អាចជួសជុលភាពមិនស៊ីសង្វាក់គ្នានៅក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* យ៉ាងដូចម្តេច នៅពេលដែលវិសាលភាពភូមិសាស្ត្រនៃសហឧក្រិដ្ឋកម្មរួម ពុំបានឆ្លុះបញ្ចាំងពីអង្គហេតុ និងបទឧក្រិដ្ឋ ដូចបានពិពណ៌នា[118]។ ម្យ៉ាងវិញទៀត ទោះបីជា សហព្រះរាជអាជ្ញាអន្តរជាតិ ទទួលស្គាល់អំពីភាពចាំបាច់ត្រូវបង្ហាញកិច្ចសហប្រតិបត្តិការរវាងជនជាប់ចោទ និងសមាជិកសហឧក្រិដ្ឋកម្មរួម នៅក្នុងការអនុវត្តគោលបំណងឧក្រិដ្ឋរួម នៅក្នុងតំបន់ភូមិសាស្ត្រដែលបានកំណត់ក៏ដោយ[119] គាត់នៅតែខកខានមិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំបានបង្ហាញភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា អោ អាន បានចូលរួម មានចេតនាប្រព្រឹត្ត ឬ បានចូលរួមចំណែកយ៉ាងសំខាន់ចំពោះបទឧក្រិដ្ឋនៅតំបន់ ៤២ និងតំបន់ ៤៣ ឬ បទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងនៅក្រៅតំបន់ ៤១ អាចជាប់ទាក់ទងនឹងក្រុមសហឧក្រិដ្ឋកម្មរួមជាអ្នកទទួលខុសត្រូវ[120]។ អាស្រ័យហេតុនេះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសនៅក្នុងការសម្រេចថា អោ អាន បានចូលរួមនៅក្នុងសហឧក្រិដ្ឋកម្មរួមនៅភូមិភាគកណ្តាល។

56. ចំណុចទី៣ សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ពុំមានកំហុស នៅពេលសំអាងលើភស្តុតាងនៃគោលនយោបាយរបស់មជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ដើម្បីកំណត់ផែនការឧក្រិដ្ឋរួមនៃសហឧក្រិដ្ឋកម្មរួម ដែលតាមការចោទប្រកាន់ អោ អាន គឺជាសមាជិក ពីព្រោះ អោ អាន និងសមាជិកផ្សេងៗទៀតនៃសហឧក្រិដ្ឋកម្មរួម ត្រូវបានចោទប្រកាន់ថាបានអនុ

---

[117] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤។ ផ្ទុយមកវិញ សូមមើល *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៦។

[118] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤។

[119] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤។

[120] ស.ច.ស.អ ព្យាយាមចោទ អោ អាន បញ្ជូនទៅជំនុំជម្រះចំពោះអំពើប្រល័យពូជសាសន៍នៅតំបន់ ៤២ និង ៤៣ ប៉ុន្តែ អំពើបែបនេះតាមផ្លូវច្បាប់ មិនអាចចាត់ទុកថាបានកើតឡើងដោយ អោ អាន តាមរយៈទម្រង់ណាមួយនៃការទទួលខុសត្រូវ រួមទាំងសហឧក្រិដ្ឋកម្មរួម នោះទេ។ ហេតុនេះ អោ អាន ត្រូវបានចោទបញ្ជូនទៅជំម្រះដោយភាន់ច្រឡំ ចំពោះអំពើប្រល័យពូជសាសន៍ជនជាតិចាមនៅភូមិភាគបូព៌ា។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៦០-១៦៣, ១៧៦។

វត្តគោលនយោបាយរបស់មជ្ឈិមទាំងនោះនៅក្នុងតំបន់ក្រោមការគ្រប់គ្រងរបស់ពួកគេ[121]។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាអន្តរជាតិ យល់មិនត្រឹមត្រូវអំពីភាពខុសគ្នារវាងគោលបំណងរួមរបស់គណៈកម្មាធិការមជ្ឈិម (ដែលគោលនយោបាយមជ្ឈិមបក្សកុម្មុយនីស្តកម្ពុជា ត្រូវបង្កើតឡើង និងផ្សព្វផ្សាយ) និងគោលបំណងរួមរបស់កម្មាភិបាលថ្នាក់ក្រោមៗ (ដែលគោលនយោបាយទាំងនេះត្រូវបានអនុវត្តនៅថ្នាក់មូលដ្ឋាន)។ គោលបំណងរួមផ្សេងគ្នាដែលត្រូវបានចោទប្រកាន់ ពុំដូចគ្នានោះទេ[122]។ ទាំង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ មិនបានបែងចែកច្បាស់លាស់រវាងក្រុមសហឧក្រិដ្ឋកម្មរួម ជាច្រើនក្រុម ដូច្នេះ ខកខានមិនបានកំណត់សហឧក្រិដ្ឋកម្មរួមជាក់ស្តែង ដែល អោ អាន ពិតជាសមាជិក គឺសហឧក្រិដ្ឋកម្មរួម ដែលមានមនុស្សច្រើននាក់ និងមានគោលបំណងរួមដូចគ្នា។

## VIII. ការឆ្លើយតបនៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅនឹងមូលដ្ឋានទី ១៤ (I) ÷ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងដោយមានកំហុសថា អំពើដោយឡែកៗពីគ្នាជាច្រើន អាចត្រូវបានសំអាងដើម្បីបំពេញលក្ខខណ្ឌនៃអំពើអមនុស្សធម៌ផ្សេងទៀត

57. សហព្រះរាជអាជ្ញាអន្តរជាតិ អះអាងដោយមានកំហុសថា “សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មិនបាន “បញ្ចូល” អាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈថាជាបទល្មើសតែមួយនោះទេ ដែលអំពើទាំងពីរនេះអាចជាបទល្មើសផ្សេងគ្នាក្រោមនិយាមអំពើអមនុស្សធម៌ផ្សេងៗទៀតរៀងៗខ្លួន ប៉ុន្តែគាត់បានវាយតម្លៃយ៉ាងត្រឹមត្រូវអំពីអំពើប្រព្រឹត្តរួមគ្នាទាំងមូល ដើម្បីកំណត់ថាតើ ធាតុផ្សំនៃអំពើអមនុស្សធម៌ផ្សេងទៀតកើតមានឬទេ”[123]។ វិធីសាស្ត្ររបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ និង សហព្រះរាជអាជ្ញាអន្តរជាតិ ពិតជាមិនត្រឹមត្រូវទាល់តែសោះ។

58. សំខាន់នោះ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា អំពើមិនមានលក្ខណៈឧក្រិដ្ឋ និងដោយ

---

[121] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ៩៤។ *ផ្ទុយមកវិញ សូមមើល បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៧។

[122] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៧។

[123] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០០។

ឡែកពីគ្នា អាចច្របាច់បញ្ចូលគ្នាដើម្បីបំពេញធាតុផ្សំនៃបទឧក្រិដ្ឋ។ វិធីសាស្ត្រនេះនាំឱ្យមានបទឧក្រិដ្ឋច្រើនខុសៗគ្នាមិនច្បាស់លាស់នៅក្នុងប្រភេទនៃអំពើមនុស្សធម៌ផ្សេងទៀត ដែលបំពានគោលការណ៍នីត្យានុកូលភាព[124]។ វិធីសាស្ត្រនេះក៏ពុំអាចឱ្យកំណត់ពីធាតុផ្សំបទឧក្រិដ្ឋនៃអំពើជាក់លាក់នីមួយៗ ដូចជា ចេតនាក្នុងការប្រព្រឹត្តិអំពើជាមូលដ្ឋាន[125]។

## IX. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី ១៦ (III) នៃបណ្តឹងឧទ្ធរណ៍ ៖ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងមិនត្រឹមត្រូវពីទឡ្ហីករណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងចេតនាជាក់លាក់នៃបទប្រល័យពូជសាសន៍

59. សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងមិនត្រឹមត្រូវពីទឡ្ហីករណ៍របស់មេធាវីការពារក្តីពាក់ព័ន្ធនឹងចេតនាជាក់លាក់នៃបទឧក្រិដ្ឋ[126]។ មិនឃើញចំណុចណាមួយនៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* លើកឡើងថា មានតែមេដឹកនាំជាន់ខ្ពស់ និងស្ថាបនិកនៃអំពើប្រល័យពូជសាសន៍នោះទេ ដែលអាចមានចេតនាអំពើប្រល័យពូជសាសន៍ជាក់លាក់ ហើយការការពារបញ្ហារបស់ថ្នាក់លើក៏មិនបានលើកឡើងផងដែរ[127]។ ផ្ទុយទៅវិញ មេធាវីការពារក្តីតវ៉ាថា នៅពេលវាយតម្លៃថាតើ អោ អាន មានចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ដែលជាលក្ខខណ្ឌតម្រូវនោះ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុស ដោយសារមិនបានពិចារណាលើភ័ស្តុតាងដែលលើកឡើងថា អោ អាន ពុំមែនជាមេដឹកនាំជាន់ខ្ពស់ ឬជាស្ថាបនិកនៃយុទ្ធនាការអំពើប្រល័យពូជសាសន៍[128]។ ក្នុង

---

[124] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៧៨ (បង្ហាញថា ស.ច.ស.អ ដាក់បញ្ចូលគ្នានូវអំពើដាក់ពីគ្នា និងខុសគ្នាដូចជាការរំលោភសេពសន្ថវៈ និងអាពាហ៍ពិពាហ៍ដោយបង្ខំ ដើម្បីឱ្យស្របតាមលក្ខខណ្ឌភាពធ្ងន់ធ្ងរនៃអំពើអមនុស្សធម៌ផ្សេងៗទៀត)។ មេធាវីការពារក្តី អះអាងថា ការបង្ហាញថាជាអំពើឧក្រិដ្ឋគឺជាលក្ខខណ្ឌតម្រូវមួយសម្រាប់អំពើអមនុស្សធម៌ផ្សេងៗទៀត។ ប៉ុន្តែ ទោះបីជាថា ការបង្ហាញថាជាអំពើឧក្រិដ្ឋ មិនមែនជាលក្ខខណ្ឌតម្រូវក៏ដោយ ក៏ វិធីសាស្ត្ររបស់សហព្រះរាជអាជ្ញាអន្តរជាតិមានកំហុស ហើយរំលោភលើគោលការណ៍នីត្យានុកូលភាព ជាពិសេសលក្ខខណ្ឌតម្រូវឱ្យមានភាពជាក់លាក់។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៨៨-១៨៩។

[125] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩០-១៩ (បង្ហាញថា ស.ច.ស.អ មិនបានបញ្ជាក់ថា អោ អាន មានធាតុផ្សំអត្តនោម័តដែលចាំបាច់ដើម្បីប្រព្រឹត្តអំពើសេពសន្ថវៈទេ)។

[126] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០៧-១០៨។

[127] *ផ្ទុយមកវិញ សូមមើល ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០៨។

[128] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩៩-២០២។ ជាងនេះទៀត មេធាវីការពារក្តី បានពឹងផ្អែកលើ រឿងក្តី *រដ្ឋអាជ្ញា តទល់នឹង Popović និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-T សាលក្រមលេខ I ថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០១០ កថាខណ្ឌ

ចំណោមកត្តាទាំងនេះ កត្តានេះពាក់ព័ន្ធនឹងការវាយតម្លៃលើចេតនាប្រព្រឹត្តអំពើប្រល័យពូជសាសន៍ ហើយលើកឡើងពីសេចក្តីសន្និដ្ឋានដ៏សមហេតុផលបែបផ្សេងថា អោ អាន ពុំមានចេតនាបែបនោះទេ[129]។

## X. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី១៧ នៃបណ្តឹងឧទ្ធរណ៍÷ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបង្ហាញថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍

60. កថាខណ្ឌនៃ*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* សហព្រះរាជអាជ្ញាអន្តរជាតិ ដកស្រង់ ពុំបង្ហាញថា គោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម ពាក់ព័ន្ធនឹងអំពើប្រល័យពូជសាសន៍ឡើយ[130]។ សហព្រះរាជអាជ្ញាអន្តរជាតិ ដកស្រង់កថាខណ្ឌពាក់ព័ន្ធនឹងការចូលរួមរបស់ អោ អាន និង កែ ពក នៅក្នុងផែនការកំណត់គោលដៅក្រុមជាក់លាក់ ពុំមែនអំពើប្រល័យពូជសាសន៍នោះទេ[131]។ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំអើពើទៅលើលក្ខខណ្ឌផ្លូវច្បាប់នៃចេតនាជាក់លាក់ចំពោះអំពើប្រល័យពូជសាសន៍នៅក្នុងគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួម[132]។ ដូច្នេះ ផ្ទុយពីការអះអាងរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ គេពុំដឹងច្បាស់ថា អំពើប្រល័យពូជសាសន៍បង្កើតជាផ្នែកមួយនៃគោលបំណងរួមរបស់ក្រុមនោះឡើយ ហើយ ដោយសារសហឧក្រិដ្ឋកម្មរួម III មិន

---

១៥១៤ ភ្ជាប់ជាឧបសម្ព័ន្ធ ២៩ និងរឿងក្តី *រដ្ឋអាជ្ញា តទល់នឹង* Popović *និងអ្នកផ្សេងទៀត* សំណុំរឿងលេខ IT-05-88-A *សាលក្រម* ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១៥ កថាខណ្ឌ ៥១៦ ភ្ជាប់ជាឧបសម្ព័ន្ធ ៣០ ដើម្បីបង្ហាញថា "ការលះបង់យ៉ាងងងឹតងងុល"របស់បុគ្គលម្នាក់ចំពោះ បក្សកុម្មុយនីស្តកម្ពុជា អាចនាំឱ្យអ្នកនោះ"ព្យាយាមយ៉ាងស្វិតស្វាញ"ដើម្បីអនុវត្តភារកិច្ចរបស់ខ្លួនដោយគ្មានចេតនាប្រល័យពូជសាសន៍នោះទេ។ សេចក្តីសន្និដ្ឋាននេះអាចអនុវត្តបានដូចគ្នាផងដែរទៅលើអ្នកដែលអនុវត្តតាមបញ្ជាដែលទទួលបានពីមេនៅក្នុងប្រព័ន្ធឋានានុក្រម ដូចជា ក.ប.ក។ មេធាវីការពារក្តី មិនបានគាំទ្រការពារបទបញ្ជាពីថ្នាក់លើនោះទេ ប៉ុន្តែនេះគ្រាន់តែជាបង្ហាញពីសេចក្តីសន្និដ្ឋានសមហេតុផលមួយដែលអាចទាញចេញពីអង្គហេតុនៅក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)*របស់ ស.ច.ស.អ តែប៉ុណ្ណោះ។ *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២០០-២០១។ ស.ច.អ មិនបានលើកឡើងពីចំណុចនេះនៅក្នុងចម្លើយតបរបស់ខ្លួនទេ។

[129] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩៩-២០២។

[130] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០៩។

[131] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០៩-១១១។ *ផ្ទុយមកវិញ សូមមើល បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២០៣-២០៥។

[132] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២០៣-២០៥។

អាចអនុវត្តបាននៅ អ.វ.ត.ក អោ អាន មិនអាចត្រូវបានកំណត់ថាជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនេះទេ។

## XI. ការឆ្លើយតបទៅនឹងចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី ១៤ (II) ១៦ (II) ១៦(III) និង ១៧ នៃបណ្តឹងឧទ្ធរណ៍ ÷ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានពុំបានបង្ហាញថា សហចៅក្រមស៊ើបអង្កេតអន្តរជាតិ រកឃើញយ៉ាងសមហេតុផលថាធាតុផ្សំនៃច្បាប់នៃបទឧក្រិដ្ឋត្រូវបានបង្ហាញគ្រប់គ្រាន់

61. ពាក់ព័ន្ធនឹងមូលដ្ឋានទី ១៤(ii) ១៦(ii) ១៦(iii) និង ១៧ នៃបណ្តឹងឧទ្ធរណ៍ សហព្រះរាជអាជ្ញាអន្តរជាតិ ពុំបានផ្តល់ទឡ្ហីករណ៍ថ្មី ឬ ពាក់ព័ន្ធ ក្រៅពីការលើកឡើងបញ្ជាក់ដដែលៗអំពីការសន្និដ្ឋានរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ[133]។ មេធាវីការពារក្តីឆ្លើយតបយ៉ាងសមស្របចំពោះការសន្និដ្ឋានទាំងនេះនៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* និងនៅតែសន្និដ្ឋានថា (ក) អោ អាន ពុំមានធាតុផ្សំអត្តនោម័តក្នុងការប្រព្រឹត្តិអំពើអមនុស្សធម៌ផ្សេងទៀតនៃការរំលោភសេពសន្ថវៈ[134] (ខ) ប្រជាជនចាមពុំត្រូវបានបញ្ជាក់អត្តសញ្ញាណ និងកំណត់គោលដៅជាមុនក្នុងប្រភេទ "ដូចជា" ដែលជាលក្ខខណ្ឌតម្រូវនៃអំពើប្រល័យពូជសាសន៍[135] (គ) អោ អាន ពុំមានចេតនាជាក់លាក់ក្នុងការប្រព្រឹត្តិអំពើប្រល័យពូជសាសន៍[136] និង (ឃ) អំពើប្រល័យពូជសាសន៍ពុំបង្កើតជាផ្នែកមួយនៃគោលបំណងរួមនៃសហឧក្រិដ្ឋកម្មរួមរបស់ក្រុម[137]។

## XII. ការឆ្លើយតបទៅនឹងចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងមូលដ្ឋានទី ១៨ នៃបណ្តឹងឧទ្ធរណ៍÷ សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន ត្រូវបានរំលោភនៅគ្រប់កិច្ចដំណើរការនីតិវិធី

62. សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានតវ៉ាដោយសមហេតុផលចំពោះទឡ្ហីករណ៍របស់មេធាវីការពារក្តីថា សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន ត្រូវបានរំលោភ

---

[133] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១០២-១០៣, ១០៦-១១១។

[134] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩១។

[135] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩៧-១៩៨។

[136] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ១៩៩-២០២។

[137] *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២០៣-២០៥។

បំពាននៅក្នុងដំណាក់កាលស៊ើបអង្កេតទាំងមូល ហើយ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ មានកំហុសដោយសារខកខានមិនបានលើកលែងការចោទប្រកាន់ ឬផ្អាកកិច្ចដំណើរការនីតិវិធីប្រឆាំងនឹងគាត់ដោយផ្អែកលើមូលដ្ឋាននេះ។ អ្វីដែលសំខាន់ជាងនេះនោះ សហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានឆ្លើយតបទៅនឹងទឡ្ហីករណ៍ចម្បងរបស់មេធាវីការពារក្តីថា ផលប៉ះពាល់ត្រួតនៃការរំលោភបំពាន បានធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរ និងមិនអាចជួសជុលបានលើភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធីក្នុងសំណុំរឿង ០០៤/២ ដែលធ្វើឱ្យការជំនុំជម្រះដោយយុត្តិធម៌ពុំអាចធ្វើឡើងនៅ អ.វ.ត.ក។

63. ចំណុចទី១ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងមិនត្រឹមត្រូវថា សច្ចធារណ៍និរទោសត្រូវបានកម្រិតត្រឹមការជំនុំជម្រះតែប៉ុណ្ណោះ (ដែលការិយាល័យសហព្រះរាជអាជ្ញាមានបន្ទុកក្នុងការបង្ហាញភ័ស្តុតាង) ហើយពុំអនុវត្តនៅក្នុងដំណាក់កាលមុនការជំនុំជម្រះនោះទេ (ដោយសារ សហព្រះរាជអាជ្ញាអន្តរជាតិពុំមានបន្ទុកបែបនេះ)[138]។ នេះគឺជាការខុសយ៉ាងច្បាស់ក្រឡែត។ ភ័ស្តុតាងបង្ហាញច្បាស់ថា អោ អាន បានទទួលសច្ចធារណ៍និរទោសតាំងពីដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីពីដើមដំបូងរហូតដល់ការចេញសេចក្តីសម្រេចស្ថាពរ[139]។ ដើម្បីឱ្យសិទ្ធិជាមូលដ្ឋានមានអត្ថន័យ

---

[138] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១៣-១១៤។ *សូមមើលផងដែរ* កថាខណ្ឌ ១២។

[139] គណៈកម្មាធិកាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ មតិយោបល់ទូទៅលេខ ៣២ មាត្រា ១៤ *សិទ្ធិស្មើភាពគ្នាចំពោះមុខតុលាការ និងសាលាក្តី និងសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌* CCPR/C/GC/32 ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០០៧ កថាខណ្ឌ ៣០ មានភ្ជាប់ជាឧបសម្ព័ន្ធ ៣១ ('ការសន្មតថាគ្មានទោស ដែលជាមូលដ្ឋានគ្រឹះនៅក្នុងការការពារសិទ្ធិមនុស្ស ដាក់បន្ទុកលើអយ្យការឱ្យបង្ហាញភស្តុតាងបញ្ជាក់ពីបទចោទ ធានាថាមិនអាចសន្មតថាមានទោសទេ ប្រសិនបើបទចោទនោះមិនអាចមានភស្តុតាងបញ្ជាក់ឱ្យហួសពីវិមតិសង្ស័យ ធានាថាជនជាប់ចោទទទួលបានប្រយោជន៍ពីវិមតិសង្ស័យ ហើយតម្រូវថាជនជាប់ចោទពីអំពើឧក្រិដ្ឋណាមួយ ត្រូវតែទទួលបានការប្រព្រឹត្តិស្របតាមគោលការណ៍នេះ')។ រឿងក្តី *Minelli តទល់នឹងស្វីស* តុលាការសិទ្ធិមនុស្សអឺរ៉ុប (ECtHR) ថ្ងៃទី២៥ ខែមីនា ឆ្នាំ១៩៨៣ កថាខណ្ឌ ៣០ ភ្ជាប់ជាឧបសម្ព័ន្ធ ៣២ ('តាមទស្សនៈរបស់តុលាការ មាត្រា 6 § 2 ចែងពីកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌទាំងអស់ ដោយមិនគិតពីលទ្ធផលនៃការចោទប្រកាន់ទេ ហើយក៏មិនត្រឹមតែពិនិត្យអង្គសេចក្តីនៃបទចោទនោះដែរ')។ សភា និងក្រុមប្រឹក្សាអឺរ៉ុប *សេចក្តីណែនាំអំពីការពង្រឹងផ្នែកមួយចំនួនអំពីការសន្មតថាគ្មានទោស និងសិទ្ធិមានវត្តមាននៅក្នុងសវនាការនៅក្នុងកិច្ចដំណើរការនីតិវិធីព្រហ្មទណ្ឌ* សេចក្តីណែនាំ(អឺរ៉ុប)លេខ 2016/343 ថ្ងៃទី ៩ ខែមីនា ឆ្នាំ២០១៦ កថាខណ្ឌ ១២ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៣ ('ការសន្មតថាគ្មានទោស គួរអនុវត្តចាប់ពីពេលដែលជនណាម្នាក់ជាប់សង្ស័យ ឬជាប់ចោទថាបានប្រព្រឹត្តបទឧក្រិដ្ឋ ឬបទឧក្រិដ្ឋតាមការចោទប្រកាន់ ហេតុនេះ គួរតែអនុវត្តសូម្បីតែមុនពេលដែលជននោះត្រូវបានអាជ្ញាធរមានសមត្ថកិច្ចរបស់សមាជិករដ្ឋណាមួយជូនដំណឹងជាផ្លូវការ ឬតាមមធ្យោបាយផ្សេងថាគាត់ជា

នោះ ការិយាល័យសហព្រះរាជអាជ្ញាត្រូវបំពេញបន្ទុកនៃការបង្ហាញភស្តុតាងនៅគ្រប់ដំណាក់កាលនៃកិច្ចដំណើរការនីតិវិធីដើម្បីអាចឲ្យរឿងក្តីដំណើរការទៅមុខ ហើយចំណុចខុសគ្នាតែមួយគត់គឺពាក់ព័ន្ធនឹង "បទដ្ឋាន" នៃការបង្ហាញភស្តុតាងនៅគ្រប់ដំណាក់កាលនីមួយៗ[140]។ ដូច្នេះ *ដោយសារ*សច្ចធារណ៍ត្រូវយកមកអនុវត្ត សហព្រះរាជអាជ្ញាមានបន្ទុកបង្ហាញ "មានហេតុផលជឿជាក់ថាឧក្រិដ្ឋកម្មដែលស្ថិតនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានកើតឡើងពិតប្រាកដ" ដើម្បីចាប់ផ្តើមកិច្ចស៊ើបសួរ[141]។ ដើម្បីចោទប្រកាន់ជនសង្ស័យ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាត្រូវបង្ហាញ "តម្រុយច្បាស់លាស់ និងស៊ីសង្វាក់គ្នា" នៃការទទួលខុសត្រូវឧក្រិដ្ឋរបស់ពួកគេ[142]។ នៅពេលបញ្ចប់កិច្ចស៊ើបអង្កេត ដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញាអនុលោមតាមវិធាន ៦៦(៦) ត្រូវធ្វើឲ្យសហចៅក្រមស៊ើបអង្កេត ជឿជាក់ថា ភស្តុតាងនៅក្នុងសំណុំរឿង "ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្រប់គ្រាន់ ដើម្បីឲ្យមានតម្លៃជាភស្តុតាងបន្ទាល់"[143] ដើម្បីអាចចោទប្រកាន់ អោ អាន ទៅជំនុំជម្រះបាន[144]។ ការមិនបំពេញបន្ទុកនៃការបង្ហាញភស្តុតាងគឺជាការបំពាន

---

ជនសង្ស័យ ឬជាជនជាប់ចោទ។ សេចក្តីណែនាំនេះគួរអនុវត្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីរហូតដល់ពេលមានសេចក្តីសម្រេចស្ថាពរកំណត់ចុងក្រោយថាតើជនសង្ស័យ ឬជនជាប់ចោទនោះបានប្រព្រឹត្តិបទឧក្រិដ្ឋដែរឬអត់')។

[140] *សូមមើល*រឿងក្តី *Bemba* សេចក្តីសម្រេចលើបទចោទ កថាខណ្ឌ ២៧, ៣១។ រឿងក្តី *Telfner ទល់នឹងអូទ្រីស* តុលាការសិទ្ធិមនុស្សអឺរ៉ុប ថ្ងៃទី២០ ខែមីនា ឆ្នាំ០០១ កថាខណ្ឌ ១៨។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិ *សេចក្តីជូនដំណឹងលេខ 1620/2007*, CCPR/C/101/D/1620/2007/Rev.2 (ថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១១) កថាខណ្ឌ ៩.៦។ *សូមមើល* ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៣៧(ប្រទេសបារាំង)។

[141] វិធានផ្ទៃក្នុង វិធាន ៥៣(១)។

[142] វិធានផ្ទៃក្នុង វិធាន ៥៥(៤)។

[143] ឧទាហរណ៍ សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយ* (*'ដីកាដំណោះស្រាយសំណុំរឿង ០០២'*) ឯកសារ **D427** ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ កថាខណ្ឌ ១៣២០-១៣២៦ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៤។

[144] *សូមមើល* វិធានផ្ទៃក្នុង វិធាន ៦៧(៣)(គ) (ចែងថា ក្នុងករណី 'ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ' សហចៅក្រមស៊ើបអង្កេត ត្រូវចេញដីកាលើកលែងចោទប្រកាន់។ ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ ២០០៧) មាត្រា ២៤៧(៣)(ប្រទេសកម្ពុជា) (ចែងថា ចៅក្រមស៊ើបសួរនឹងចេញដីកាលើកលែងចោទប្រកាន់ក្នុងករណី 'គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ')។ ក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ១៨៤(ប្រទេសបារាំង)។ ទោះបីជាថា ទាំង *វិធានផ្ទៃក្នុង* ទាំង *ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា (ឆ្នាំ០០៧)* មិនបានកំណត់និយមន័យអំពីបទដ្ឋាន"ភស្តុតាងគ្រប់គ្រាន់"យ៉ាងណាក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត បានធ្វើដូច្នេះនៅក្នុងសំណុំរឿង ០០១, ០០២ និង ០០៤/១ ដែរ។ សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍សំណុំរឿង ០០៤/១ កថាខណ្ឌ ៦១-៦២។ សំណុំរឿង ០០៤/១/០៧-០៩-២០០៩ អ.វ.ត.ក-ក.ស.ច

យ៉ាងជាក់លាក់លើដំណើរការនីតិវិធីតាមផ្លូវច្បាប់ *ដោយសារ* ជនសង្ស័យ ឬ ជនត្រូវចោទ ត្រូវបានសន្មតជាមុនថាគ្មានទោសនៅក្នុងដំណាក់កាលនីតិវិធីទាំងមូល។ ខុសពីប្រព័ន្ធផ្សេងទៀតដែលសហព្រះរាជអាជ្ញាអន្តរជាតិ បានលើកឡើង[145] នៅ អ.វ.ត.ក សេចក្តីសម្រេចចោទប្រកាន់បញ្ជូនរឿងទៅជំនុំជម្រះធ្វើឡើងដោយ សហចៅក្រមស៊ើបអង្កេតពីររូប ដោយផ្អែកលើ និងកម្រិតដោយរឿងក្តីរបស់ការិយាល័យព្រះរាជអាជ្ញា ដូចបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម និងដីកាសន្និដ្ឋានស្ថាពរ[146]។ ដូច្នេះ បើទោះជាសហព្រះរាជអាជ្ញាអន្តរជាតិ ខកខានមិនបានធ្វើឲ្យសហចៅក្រមស៊ើបអង្កេតជាតិ *និង* ចៅក្រមភាគច្រើនរបស់ អង្គបុរេជំនុំជម្រះ ជឿក៏ដោយ ការបញ្ជូន អោ អាន ទៅជំនុំជម្រះគឺជាការរំលោភធ្ងន់ធ្ងរដល់សច្ចធារណ៍និរទោសចំពោះ អោ អាន។ ការសម្រេចផ្ទុយពីនេះ នឹងធ្វើឲ្យសច្ចធារណ៍ប្រែគ្មានន័យ។

64. ចំណុចទី២ ការតវ៉ារបស់ សហព្រះរាជអាជ្ញាអន្តរជាតិ ចំពោះការរំលោភសិទ្ធិនីតិវិធីដែលបានលើកឡើងដោយមេធាវីការពារក្តី អោ អាន ត្រូវបានកម្រិតត្រឹមការលើកឡើងថា គ្មានកំហុស ឬ ព្យសនកម្មនោះទេ ដោយពុំបានផ្តល់ទឡ្ហីករណ៍ ឬ មូលដ្ឋានសំអាងបន្ថែមអ្វីសោះឡើយ[147]។ ផ្ទុយទៅវិញ

.ស *ដីកាដំណោះស្រាយ (សំអាងហេតុ)* ឯកសារ **D308/3** ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០១៧ កថាខណ្ឌ ២ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៥។ *ដីកាដំណោះស្រាយសំណុំរឿង ០០២* កថាខណ្ឌ ១៣២១-១៣២៣។ សំណុំរឿង ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស *ដីកាដំណោះស្រាយ* ឯកសារ **D99** ថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៨ កថាខណ្ឌ ១៣០ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៦។ នៅក្នុងសំណុំរឿង ០០២សហចៅក្រមស៊ើបអង្កេត បានបកស្រាយថា "ភស្តុតាងគ្រប់គ្រាន់"មានន័យថាជាភវនីយភាពនៃពិរុទ្ធភាព មិនមែនគ្រាន់តែភាពអាចមានពិរុទ្ធទេ។ នៅកថាខណ្ឌ ១៣២៣ នៃ*ដីកាដំណោះស្រាយសំណុំរឿង ០០២* បានពន្យល់ថា ភស្តុតាងនៅក្នុងសំណុំរឿង 'ត្រូវមានលក្ខណៈខ្លាំងក្លា និងស៊ីសង្វាក់គ្នាគ្រប់គ្រាន់ដើម្បីឲ្យមានតម្លៃជាភស្តុតាងបន្ទាល់'ដែលបញ្ជាក់ថា ជនត្រូវចោទអាចមានពិរុទ្ធភាព។ *សូមមើលផងដែរ* 'Chapitre 613 "Appréciation du juge d'instruction"', section 1, in Guéry & Chambon (ed.), *Droit et pratique de l'instruction préparatoire* (Dalloz action 2015) កថាខណ្ឌ ៦១៣.១២ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៧។

[145] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១៤។

[146] វិធានផ្ទៃក្នុង វិធាន ៥៥(២) (ចែងថា 'សហចៅក្រមស៊ើបអង្កេតត្រូវធ្វើការស៊ើបសួរតែអង្គហេតុណា ដែលមានចែងក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរ ឬ ដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរបន្ថែម')។

[147] សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងទាំងមិនត្រឹមត្រូវថា បញ្ហានានាដែលបានលើកឡើងពីមុននៅចំពោះមុខ អ.ប.ជ ដែលមិនទាន់ត្រូវបានសម្រេចសេចក្តីដោយសារមិនអាចរកបានសំឡេងភាគច្រើននោះ ត្រូវមានសំអាងហេតុដើម្បីឲ្យពិចារណាឡើង

ការរំលោភបំពាន និងព្យសនកម្មដែលនឹងកើតឡើង ត្រូវបានបង្ហាញ និងលើកយុត្តិកម្មនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន*[148]។

65. ចំណុចទី៣ សហព្រះរាជអាជ្ញាអន្តរជាតិ បង្ហាញពីជំហររបស់មេធាវីការពារក្តីស្តីពីវិបត្តិថវិការបស់តុលាការ និងផលប៉ះពាល់លើសិទ្ធិរបស់ អោ អាន ថាជា "ការទាយស្មាន" ដោយលើកឡើងថា អង្គបុរេជំនុំជម្រះ អង្គជំនុំជម្រះសាលាដំបូង និង អង្គជំនុំជម្រះតុលាការកំពូល មានភារកិច្ចធានាសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ អោ អាន[149]។ នៅពេលលើកឡើងដូច្នេះ គាត់បានច្រានចោលការព្រមានរបស់សហចៅក្រមស៊ើបអង្កេត ថា កង្វះថវិកានឹងរារាំងចៅក្រមដែលទទួលរឿងក្តីរបស់ អោ អាន នាពេលអនាគត មិនអាចបញ្ចប់កិច្ចដំណើរការនីតិវិធី ឬ ការធានាសិទ្ធិរបស់គាត់[150] និងមិនទទួលស្គាល់អំពីវិបត្តិថវិកាជាក់ស្តែង (ពុំមែនការទាយស្មាន) ដែលតុលាការយល់ដូច្នេះនៅក្នុងពេលបច្ចុប្បន្ននេះ[151]។

66. ទឡ្ហីករណ៍សំខាន់របស់មេធាវីការពារក្តីដែលថា ផលប៉ះពាល់គ្រួតគ្នានៃការរំលោភសិទ្ធិនៅក្នុងដំណាក់កាលស៊ើបអង្កេតទាំងមូល ពុំអាចធ្វើឱ្យមានការជំនុំជម្រះដោយយុត្តិធម៌ ត្រូវបានបង្ហាញយ៉ាងច្បាស់ដោយសារមិនឃើញមានលើកឡើងនៅក្នុង *ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ*។ ហេតុផលដូចបានលើកឡើងនៅក្នុង *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ផ្តល់យុត្តិកម្មសមហេតុផលដល់ការពិនិត្យការរំលោភបំពានទាំងអស់ដែលបានលើកឡើងក្រោមមូលដ្ឋាននេះ (មិនថាបាន ឬ មិនបានលើកឡើងពីមុននោះទេ) នៅពេលពិចារណាលើផលប៉ះពាល់គ្រួតគ្នា និងនៅក្នុងបរិបទនៃការស៊ើបអង្កេតទាំងមូល[152]។

---

វិញដើម្បីបង្កើតបានជាកំហុសងាយឃើញ។ តាមនិយមន័យ បញ្ហាមួយដែលមិនទាន់ត្រូវបានសម្រេច នៅតែជាបញ្ហា "ដែលមិនត្រូវបានសម្រេចសេចក្តី។ ការប្រើប្រាស់ពាក្យ "ពិចារណាឡើងវិញ"គឺជាការប្រើប្រាស់ពាក្យមិនត្រឹមត្រូវ"។

148 *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២១៣-២១៨។

149 *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១៨។

150 សំណុំរឿង ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក/ក.ស.ច.ស *សំណើសុំមតិយោបល់អំពីស្ថានភាពថវិការបស់ អ.វ.ត.ក និងផលប៉ះពាល់មកលើសំណុំរឿង ០០៣ សំណុំរឿង ០០៤ និងសំណុំរឿង ០០៤/២* ឯកសារ **D349** ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០១៧ កថាខណ្ឌ ៥២-៥៤, ៥៨។

151 *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២២០-២២១។

152 *បណ្តឹងឧទ្ធរណ៍របស់ អោ អាន* កថាខណ្ឌ ២២៣-២២៧។

67. ចំណុចចុងក្រោយ សហព្រះរាជអាជ្ញាអន្តរជាតិ លើកឡើងថា ការរំលោភសិទ្ធិទាំងនេះគួរត្រូវបញ្ជូនត្រឡប់ទៅ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ វិញ ដើម្បីផ្តល់ "ដំណោះស្រាយសមស្រប"[153]។ នៅពេលធ្វើដូច្នេះ គាត់ពុំបានអើពើលើយុត្តិសាស្ត្រច្បាស់ដែលថា នៅក្នុងករណីពុំអាចជួសជុលព្យសនកម្ម ឬ ការគំរាមធ្ងន់ធ្ងរលើកិច្ចដំណើរការនីតិវិធី ចៅក្រមមានភារកិច្ចបញ្ចប់កិច្ចដំណើរការនីតិវិធីតាមរយៈការលើកលែងការចោទប្រកាន់លើរឿងក្តី ឬការបង្គាប់ឲ្យផ្អាកជាអចិន្ត្រៃយ៍[154]។ ភារកិច្ចធានាភាពយុត្តិធម៌ និងសុចរិតភាពនៃកិច្ចដំណើរការនីតិវិធី និងសិទ្ធិជាមូលដ្ឋានរបស់ អោ អាន នាពេលនេះ ជាបន្ទុករបស់ អង្គបុរេជំនុំជម្រះ [155]។ អាស្រ័យហេតុនេះ មេធាវីការពារក្តីស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ ច្រានចោល*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)* និងលើកលែងការចោទប្រកាន់លើរឿងក្តីរបស់ អោ អាន។

## សេចក្តីសន្និដ្ឋាន និងសំណើសុំ

68. យោងតាមហេតុផលដូចបានពន្យល់ខាងលើ *ចម្លើយតបរបស់ សហព្រះរាជអាជ្ញាអន្តរជាតិ* ខកខានមិនបានតវ៉ាទៅនឹងទឡ្ហីករណ៍ដែលបានលើកឡើងនៅក្នុង*បណ្តឹងឧទ្ធរណ៍របស់ អោ អាន* ពាក់ព័ន្ធនឹងកំហុសអង្គច្បាប់ និងអង្គហេតុជាច្រើនរបស់ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ក្នុង*ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ)*។ នៅក្នុងចម្លើយតបរបស់ខ្លួន សហព្រះរាជអាជ្ញា

---

[153] *ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ* កថាខណ្ឌ ១១៩។

[154] សំណុំរឿង ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក(២៨) *សេចក្តីសម្រេចលើបណ្តឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្តីសម្រេចលើកទីពីររបស់អង្គជំនុំជម្រះសាលាដំបូងស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿង ០០២* ឯកសារ **E284/4/8** ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៣ កថាខណ្ឌ ៧៥ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៨។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Brđanin *និង* Talić សំណុំរឿងលេខ IT-99-36 *សេចក្តីសម្រេចលើសំណើលើកទីពីររបស់* Brđanin *សុំលុបចោលដីកាបញ្ជូនទៅជំនុំជម្រះ*ថ្ងៃទី១៦ ខែឧសភា ឆ្នាំ២០០១ កថាខណ្ឌ ៥ ភ្ជាប់ជាឧបសម្ព័ន្ធ ៣៩។ *សូមមើលផងដែរ* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Milošević សំណុំរឿងលេខ IT-02-54-AR73.4 *មតិយោបល់ជំទាស់របស់ចៅក្រម* David Hunt *អំពីភាពអាចទទួលយកភស្តុតាងជាពិសេសទម្រង់ជាការចម្លើយជាលាយលក្ខណ៍អក្សរ* ថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៣ កថាខណ្ឌ ២១ ភ្ជាប់ជាឧបសម្ព័ន្ធ ៤០។ *សូមមើល* រឿងក្តី *រដ្ឋអាជ្ញាតទល់នឹង* Lubanga Dyilo សំណុំរឿងលេខ ICC-01/04-01/06 *សេចក្តីសម្រេចលើផលប៉ះពាល់ដោយសារមិនដាក់បង្ហាញភស្តុតាងដោះបន្ទុកដែលមានចែងនៅក្នុងកិច្ចព្រមព្រៀង មាត្រា ៥៤(៣)(ង) និងពាក្យសុំផ្អាកការចោទប្រកាន់លើជនជាប់ចោទ រួមជាមួយនឹងបញ្ហាមួយចំនួនផ្សេងទៀតដែលបានលើកឡើងនៅក្នុងសន្និសីទស្តីពីលក្ខន្តិកៈ ថ្ងៃទី ១០ ខែមិថុនា ឆ្នាំ០០៨* ថ្ងៃទី១៥ ខែមិថុនា ឆ្នាំ០០៨ កថាខណ្ឌ ៩២-៩៥ ភ្ជាប់ជាឧបសម្ព័ន្ធ ៤១។

[155] *ដីកាដំណោះស្រាយ (ដីកាបញ្ជូនទៅជំនុំជម្រះ)* កថាខណ្ឌ ៤៤។

អន្តរជាតិ យល់ខុស ឬលើកឡើងមិនត្រឹមត្រូវអំពីទឡ្ហីករណ៍របស់មេធាវីការពារក្តី និងបានពង្រីកច្បាប់ និងអង្គហេតុជាធរមាន ដើម្បីព្យាយាមផ្តល់យុត្តិកម្ម ឬធ្វើកុំឲ្យមើលឃើញកំហុសទាំងនេះ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមគោរពស្នើសុំឲ្យ អង្គបុរេជំនុំជម្រះ ទទួលយក និងយល់ព្រមតាមបណ្តឹងឧទ្ធរណ៍របស់ អោ អាន (និងតម្កល់ *ដីកាលើកលែងការចោទប្រកាន់)*។

សូមលោកចៅក្រមទទួលយកចម្លើយតបនេះដោយក្តីគោរពពីយើងខ្ញុំ។

ធ្វើនៅរាជធានីភ្នំពេញនៃព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ០១ ខែមេសា ឆ្នាំ២០១៩

**សហមេធាវីការពារក្តីរបស់លោក អោ អាន**

| | | |
|---|---|---|
| មុំ លុជ្ស | Richard ROGERS | Göran SLUITER |